## វគ្គ

## វិញ្ញាណមកតាម

នៅតាមផ្លូវវិលមកផ្ទះរហូតដល់ថ្ងៃវិលមករៀននៅភ្នំពេញវិញ ខ្ញុំតែងតែរំពៃតាមផ្លូវរកសម្គាល់មើលប្រភេទដើមឈើបែកមែកជាពីរមានរាងជាចម្លាមដូចដែលពុកខ្ញុំបាននិយាយប្រាប់។ នៅតាមបណ្តោយផ្លូវសាធារណៈ មិនខ្វះអីដើមឈើដែលមានរូបរាងប្រភេទនេះ តែនៅក្នុងលំនៅដ្ឋាននានាវិញ គឺមិនឃើញមានសោះឡើយ។

យប់ទីមួយ មកដល់កុដិវិញ ខ្ញុំអស់កម្លាំងយ៉ាងខ្លាំង ក៏ប្រះភ្លាមផ្ទេចលក់មួយភ្លឹបទៅ។ ខ្ញុំចាប់ផ្តើមយល់សុបិនអំពីអ្វីមួយដែលមើលទៅរញ៉េរញ៉ៃមិនច្បាស់លាស់ ហើយសុទ្ធសឹងជាបញ្ហាស្មុគស្មាញ ខឹងណែនទ្រូង ឬតូចចិត្តពិបាកក្នុងចិត្ត តែរកមូលហេតុច្បាស់មិនឃើញឡើយ។ សូម្បីតែឱ្យរកនឹកឡើងវិញថា យប់មិញយល់សប្តិឃើញអ្វី ក៏រកនឹកមិនឃើញ ដឹងតែថាជាយល់សប្តិដែលធ្វើឱ្យគេងមិនបានស្ងប់ ហើយអស់កម្លាំងលើសដើម។

«អាថា! អ្វែងបានស្រីពីណាមកឱបកាត់សួនច្បារ?»

អាសាន់ វាចូលមកដល់កុដិ ហើយនិយាយបែបនេះ។ ខ្ញុំយល់ថា វាតែងចំអកឱ្យខ្ញុំ ដូច្នេះជារឿយៗ អ៊ីចឹងហើយ លើកនេះកំពុងមិនសូវមានសុខភាពល្អ ខ្ញុំដេកចុចទូរសព្ទធម្មតាខ្ជិលឆ្លើយតបអ្វីនឹងវា។

ទំនងឃើញមុខខ្ញុំមាំ អាសាន់ក៏មិនហ៊ានមករញ៉េរញ៉ៃអីបន្ថែមដែរ។

យប់ដដែល ខ្ញុំយល់សប្តិឃើញស្រីម្នាក់យំយែកមិនឈប់ឈរ តែខ្ញុំមិនដឹងថានាងជាអ្នកណាទេ ហើយយំរឿងអ្វី មុខនាងដូចម្តេច ក៏ខ្ញុំមិនដឹង ដឹងតែថា នាងយំមិនឈប់យំឡើងរងំក្នុងត្រចៀកធ្វើខ្ញុំភ្ញាក់ឡើងមកទាំងមួហ្មង។

ដោយសារថ្ងៃនេះ មានមិត្តម្នាក់ដែលស្នាក់នៅក្បែរកុដិនេះដែរ គេមានប្អូនស្រីរៀបការនៅខេត្តកណ្តាល បាយថ្ងៃត្រង់រួចរសៀលប្រមាណម៉ោងជិតពីរ ពួកខ្ញុំចេញដំណើរទៅហូបការគេ។ គ្នាខ្ញុំប្រាំនាក់ជិះម៉ូតូបីគ្រឿង។ ម្ចាស់ដើមការ គេមិនចង់ឱ្យពួកយើងជិះមកវិញយប់ពេក ហើយក៏មិនចង់ឱ្យបកមកវិញឆាប់ពេក គេក៏រកកន្លែងគេងទទួលពួកខ្ញុំមួយយប់។ វាជាផ្ទះល្វែងមួយមានបន្ទប់គេងពីរនៅក្បែរផ្សារ តែមិនអ៊ូអរដូចភ្នំពេញទេ។

ប្លុកផ្ទះល្វែងនេះចាស់ណាស់ដូចជាត្រូវបានគេកសាងឡើងតាំងពីសម័យអាណានិគម។ តាមថាវាពិបាកគេងណាស់ ប្លែកកន្លែង ហើយផ្ទះល្វែងនេះចាស់ហាក់ខានមានគេគេងយូរហើយ ទោះបីជាវា

មិនកខ្វក់ តែវាពិតជាចាស់អាចធ្វើឱ្យអ្នកល្មមៗមានអារម្មណ៍ថាខ្លាចបាន។ ម៉ោងប្រហែលជា ១១ យប់ គេស្រវឹងដេកអស់។ គ្មានអ្នកណាចូលដេកបន្ទប់ទេ គឺក្រាលកន្ទេល ព្រមទាំងដេកប៉ោអ៊ីក្បែរៗទ្វារមុខតែម្តង។

ដោយស្រវឹងស្រៀងៗ ខ្ញុំក្រោកចូលទៅរកបន្ទប់ទឹក។ ទីតាំងបន្ទប់ទឹកគឺនៅកំណាត់ចុងខាងក្រោយផ្ទះល្វែង។ ខ្ញុំត្រូវដើរកាត់បន្ទប់ដេកពីរនោះសិន ទើបទៅដល់ក្រោយបាន។ អំពូលភ្លើងពណ៌សបើកចោលតែនៅខាងមុខផ្ទះ និងកន្ទុយក្រោយត្រង់បន្ទប់ទឹក និងចង្ក្រាន ដូច្នេះនៅតាមបណ្តោយផ្លូវគ្រប់យ៉ាងគឺងងឹតច្រើនជាងទទួលបានពន្លឺ។

មិនដឹងយ៉ាងម៉េចទេ ពេលដើរដល់បន្ទប់ទីពីរ ក៏កន្ទុយភ្នែកហាក់ក្រឡេកឃើញមនុស្សឈរ។ ជាមនុស្សស្រីច្បាស់តែម្តង គ្រាន់តែមិនបានឃើញមុខ។ ខ្ញុំស្រាប់តែទទួលអារម្មណ៍ព្រឺសម្បុរជាមួយនឹងការភ័យខ្លាច។ ទោះបីខ្ញុំបានដើរហួសមកដល់ខាងក្រោយហើយ ខ្ញុំនៅតែគិតថាមាននរណាម្នាក់នៅទីនោះប្រាកដណាស់ ហើយគេកំពុងឈរម្នាក់ឯងក្នុងបន្ទប់ងងឹត។

បន្ទោបង់ប្រញាប់ប្រញាប់ ខ្ញុំវិលមកប្រះដេកវិញភ្លាម ដោយដើរលឿនដូចហោះ ព្រមទាំងបិទភ្នែកមិនព្រមសម្លឹងអ្វីទាំងអស់តាមបណ្តោយផ្លូវ។

«យប់មិញ ខ្មោចលងអញអានេះ!»

មិនមែនសម្តីខ្ញុំនិយាយទេ គឺសំឡេងអាសាន់ វារៀបរាប់ប្រាប់ម្នាក់ឈ្មោះសារុំ ដែលជាបងប្រុសសាមីខ្លួនម្ចាស់ពិធីមង្គលការល្ងាចមិញ។

ខ្ញុំមិនដឹងថា សារុំឮហើយមានប្រតិកម្មបែបម៉េចទេ ព្រោះខ្លួនឯងកំពុងជូតខ្លួនក្នុងបន្ទប់ទឹក ចំណែកអ្នកទាំងពីរកំពុងជជែកគ្នានៅខាងក្រៅ។

«ខ្មោចស្រីមកទាញភួយ មកទាញជើង! យំយែក អង្គុយសំកុកពេញផ្ទះ! ដូចកំពុងទួញរកអ្នកណា!»

អាសាន់និយាយរអ៊ូដាក់ម្ចាស់ផ្ទះបន្ថែម ធ្វើឱ្យខ្ញុំកាន់តែនឹកឃើញឡើងវិញអំពីអ្វីដែលបានឃើញកាលពីយប់។ ខ្ញុំស្រែករំលងជញ្ជាំងបន្ទប់ទឹកប្រាប់ទៅអាពីរនាក់នៅខាងក្រៅ៖

«អញស្រវឹងដើរមកនោម អញដូចរវើរវាយឃើញស្រីម្នាក់ឈរដែរអ្ហា!»

ស្ងាត់គ្មានឮសារុំឆ្លើយអ្វី ខ្ញុំស្លៀកពាក់រួច ក៏ចេញមកក្រៅរៀបចំឡើងទៅភ្នំពេញវិញ។ មកដល់បន្ទប់ខាងក្រៅដែលនាំគ្នាដេកកាលពីយប់មិញ ខ្ញុំឃើញសារុំកំពុងរៀបចំបោសសម្អាត ហើយបត់ខ្នើយភួយទុក។ ខ្ញុំជួយបត់ប៉ោអ៊ីឡើង ហើយនិយាយលើកទឹកចិត្ត៖

«អ្ហែងកុំយកសម្ដីពួកអញគិតពេក! មនុស្សស្រវឹងយកជាការមិនបានទេអើយ!»

ខ្ញុំទះស្មារវា ស្រាប់តែសារ៉ុត្អូញមកវិញខ្សឹបៗ៖

«កុំថាតែពួកអ្ហែង អញក៏យល់សប្ដិឃើញស្រីសក់វែងដែរ! វាច្របាច់កអញ!»

មាត់ខ្ញុំកំពុងទំពាអន្សម ស្រាប់តែគាំង។ ទឹកមុខសារ៉ុក៏ទំនងជាមិនបានដេកស្កប់ដូចគ្នា។ គេនោះនិយាយមកបន្ថែមទាំងក្រពុលមុខ៖

«ពិបាកដែរ! ផ្ទះទុកចោលយូរអត់មនុស្សនៅ! តោះរួចរាល់នៅ? នាំគ្នាទៅ! អញចាក់សោ»

បានមួយអាទិត្យក្រោយមក ខ្ញុំសឹងភ្លេចរឿងមនុស្សស្រីនោះទៅហើយ ស្រាប់តែគេងភ្ញាក់ឡើងនៅទៀបភ្លឺ ក៏មានអារម្មណ៍ថានរណាម្នាក់កំពុងស្ទាបកំភួនដៃរបស់ខ្ញុំ។

គ្នាយើងសុទ្ធតែប្រុសៗ រឿងលូកដៃមកស្ទាបគ្នា មិនអាចកើតឡើងដាច់ខាត។ ខ្ញុំភ្ញាក់ដូចគេកន្ត្រាក់ក្រោកឡើងទាំងសើងម៉ើងទទឹងទទែង។ ទម្រាំរម្លឹកមកវិញ ដឹងថាខ្លួនឯងមិនបានដេកក្នុងកុដិទេ គឺកំពុងដេកបន្ទប់ជួលរបស់មិត្តចាស់ម្នាក់ឈ្មោះដារិទ្ធ ហើយខ្ញុំនាំអាសាន់មកដែរ។

អ្វីដែលចម្លែកគឺទិដ្ឋភាពទីនេះស្ងាត់ឈឹង ពីរនាក់ទៀតនៅគេង គ្រប់យ៉ាងគឺធម្មតា ហើយក៏មិនមានមនុស្សស្រីណានៅក្នុងមុងខ្ញុំដែរ ចុះពីណាទៅដែលមុននេះមកអង្អែលដៃខ្ញុំ?

ទាញទូរសព្ទមកចុចមើលម៉ោង ម៉ោង ៣ កន្លះភ្លឺ។

ខ្ញុំធ្មេចភ្នែកទាំងគិតថា ខ្មោចលងពិតហើយ គ្រាន់តែខ្ញុំមិនឆោឡោខ្មាសអ្នកដេកបន្ទប់ជាមួយគ្នាព្រោះពួកវាកំពុងតែស្រមុកខុរៗ។

ប៉ុន្តែទោះប្រឹងបិទភ្នែកយ៉ាងណា ខ្ញុំកាន់តែដេកមិនលក់ ចុងក្រោយ ប្រាកដណាស់ថាបានឮសូរសំឡេងមនុស្សស្រីខាកស្ដោះក្នុងបន្ទប់ទឹក។ ខ្ញុំផ្ទៀងត្រចៀកស្ដាប់ គឺច្បាស់ណាស់ថាមានមនុស្សផ្សេងកំពុងសំងំក្នុងបន្ទប់ទឹក ហើយត្រចៀកបានឮស្នូរជើងដើរច្រប់ចុះឡើង។ កាន់តែធ្មេចធ្វើមិនដឹងសូរសម្រិបនោះកាន់តែឮច្បាស់មក។

«អាណានាំស្រីមក?»

ខ្ញុំឱនទៅខ្សឹបសួរមិត្តដែលដេកស្ងាត់លើគ្រែក្បែរៗគ្នាធ្វើឱ្យដារិទ្ធ ដែលជាម្ចាស់បន្ទប់គំហកមកវិញតិចៗថា «ដេកទៅ!»។ ខ្ញុំព្រឺសម្បុរជាមួយនឹងការភ័យខ្លាច។ សម្ដីខ្លីរបស់ដារិទ្ធដូចជាមិនបដិសេធទេ

ថាមាននរណាម្នាក់នៅទីនោះ ឬមួយថាគេពិតជាបានឮដូចខ្ញុំ គ្រាន់តែមិនចង់ឱ្យខ្ញុំដេញដោល។ គ្មានវិធីណាអាចកំណត់ការពិតរបស់សំឡេងនោះបានទេ មានតែម្យ៉ាងគត់គឺក្រោកទៅមើល។

ចិត្តមួយរវ៉ាច់ថា ខ្ញុំជាមនុស្សប្រុស ហើយខ្ញុំមានមិត្តពីរនាក់ដេកនៅទីនេះដែរ តើខ្ញុំខ្លាចធ្វើអី បន្ទប់ជួលតូចមួយក្រវេច។

សំងំគិតបានប្រហែល ៥ នាទី ខ្ញុំសម្រេចចិត្តបង្កើនភាពក្លាហានដើម្បីក្រោកចេញពីគ្រែដើរទៅបន្ទប់ទឹក។ ខ្ញុំមិនហ៊ានចុចភ្លើងបើកទេ ខ្លាចរំខានគេឯង ខ្លាចអាសាន់ និងដារិទ្ធរអ៊ូខឹង ដូច្នេះបានត្រឹមបើកពិលទូរសព្ទ។

ប្រហែលជាឃើញខ្ញុំដើរលបៗហើយ បានជាដារិទ្ធស្រែកប្រាប់មកវិញថា៖

«អ្ហែងមិនបើកភ្លើង?»

ខ្ញុំចុចភ្លើងបំភ្លឺភ្លឺថែស។ គ្មានអ្នកណាទាំងអស់។

«អញឮសំឡេងមនុស្សស្រីក្អកកណ្ដាស់ច្បាស់ណាស់!»

អាសាន់និយាយតបពីក្នុងមុងមកដោយសំឡេងឡុលៗ៖

«អ្ហែងនេះមមើមមាយហួសហេតុពេកហើយអ្ហា ម៉ោងមិនទាន់ ៤ ភ្លឺផង!»

បានសេចក្ដីថាគ្មានអ្នកណាម្នាក់មានអារម្មណ៍ឮអ្វីដូចខ្ញុំទេ?

ខ្ញុំមិនមាត់មិនកប្រះដេកវិញ តែរោមនៅលើកំភួនដៃនៅតែបះព្រោងនៅឡើយ។ ស្អែកឡើង ទាំងមានអារម្មណ៍មិនល្អ ខ្ញុំចេញមកសំកុកនៅហាងកាហ្វេ។

កំពុងរង់ចាំផឹកកាហ្វេ ព្រោះគេងមិនឆ្អែត ស្រាប់តែលេខម៉ែខលមកពីផ្ទះ។

«ថ្ងៃសៅរ៍នេះមកផ្ទះអត់ទេកូន? ម៉ែយល់សប្ដិមិនល្អ!»

«ម៉ែឃើញអីម៉ែ? មនុស្សកំពុងស្មុគ!»

«ស្មុគស្មាញខ្លះអ្ហាកូន? នែ ចន្ថា! ម៉ែយល់សប្ដិឃើញកូនឯងឱបបង្វេចនាំមនុស្សស្រីមកផ្ទះ! នាងនោះមកដល់ចូលក្នុងផ្ទះ ហើយក៏មិនព្រមនិយាយរកពីណាសោះ! ពេលម៉ែតាមសួរ ឃើញនាងងាកមកមានមុខខ្មៅដូចព្រាយ ហើយម៉ែក៏ដឹងខ្លួនព្រឺបមកវិញទាំងបែកញើសត្រជាក់ស្រឹបភ័យបះដៃបះជើង!»

ខ្ញុំក្តុកចិត្តខ្វល់ភ័យ។ គាត់យល់សប្តិបន្ថែមពីលើស្ថានភាពខ្ញុំដែលកំពុងសៅហ្មងស្រាប់។ សម្រាប់ខ្ញុំពេលនេះ បើមិនពិភាក្សានឹងម៉ែ តើគួររកពីណាមកពិភាក្សាវិញ?

ខ្ញុំដាច់ចិត្តថានិយាយប្រាប់ម៉ែ ដោយថយមកឆ្ងាយពីគេឯង ហើយខ្សឹបដាក់គាត់៖

«ម៉ែអ្ហា មួយរយៈនេះ ខ្ញុំឧស្សាហ៍មានអារម្មណ៍ថាត្រូវខ្មោចលងដល់ហើយម៉ែ!»

«ថ្ងៃសៅរ៍អាទិត្យនេះ មកផ្ទះវិញសិនមកកូន ម៉ែរកលោកស្រោចទឹកឱ្យ!»

«ខ្ញុំនៅវត្តស្រាប់ហើយម៉ែ!»

ដោយនិយាយបន្ថែមរអ៊ូៗ គាត់និយាយទាំងសំឡេងបារម្ភ។ ខ្ញុំវិញមិនសូវខ្វល់ពីចិត្តគាត់ប៉ុន្មានទេ គិតតែពីបង្ហាញចិត្តខ្លួនឯង៖

«ជិតភ្លឺ ទៅជាដេកមិនលក់ ស្រមៃថាមានខ្មោចស្រីមួយមកស្ទាបដៃ ឡើងព្រឺ! ក្រោកមក ឮសូរសំឡេងមនុស្សក្អកគ្រហែមក្នុងបន្ទប់ទឹក ជាសំឡេងមនុស្សស្រីដល់ពេលទៅរកមើល អត់មានឃើញអីសោះ!»

«ចុះថ្ងៃសៅរ៍នេះ មកផ្ទះបានអត់កូន?»

«ចាំខ្ញុំគិតមើលសិនម៉ែ!»

និយាយតាមពិតទៅ យុវវ័យដូចខ្ញុំសម្បូរកម្មវិធីបំផុតនៅសៅរ៍អាទិត្យហ្នឹងហើយ អ៊ីចឹងបានថា ភាគច្រើនខ្ញុំមិនសូវចង់ទៅផ្ទះប៉ុន្មានទេ។ ពាក្យ «ចាំគិតមើលសិន» គឺមានន័យថា ភាគរយច្រើនគឺ «អត់» ។

ហាក់ដឹងចរិតខ្ញុំ ម៉ែឆ្លៀតសង្កត់បន្ថែម៖

«កុំលេងៗណាកូន! ម៉ែកម្រយល់សប្តិប្លែកអ៊ីចឹងណាស់! ហើយយល់សប្តិជិតភ្លឺទៀត ម៉ែមិនសូវស្រណុកចិត្តទេ! គេថាយល់សប្តិជិតភ្លឺជាសុបិននិម្មិត! អ្នកណាចង់ប្រាប់យើងអ្វីមួយហើយ!»

«ហ៊ឺមកុំខ្វល់ហួសហេតុពេកម៉ែ! បើទំនេរ ខ្ញុំទៅហើយ!»

ទោះបីនិយាយអ៊ីចឹងមែន ខ្ញុំនៅតែមានអារម្មណ៍ស្មុគស្មាញមិនសុខមិនសាប់ពេញមួយថ្ងៃ។ លុះព្រលប់ធំ ខ្ញុំវិលមកកុដិ។ ម៉ូតូខ្ញុំស្រាប់តែរលត់ខូច។ មេឃងងឹតមើលគ្នាឃើញព្រាលៗ ខ្ញុំនឹកខ្ជិលផងអស់កម្លាំងផង គិតថាចាំព្រឹកចាំរកគេប៉ះ។

អូសម៉ូតូកាត់តាមតូបមីងលក់សាំង គាត់ស្រែកមកទាំងសើចស្វាញ៖

«អន្និតអើយ ថ្ងៃនេះម៉ូតូខូច អត់ដឹកសង្សារមកទេ?»

ខ្ញុំចងចិញ្ចើមមិនសប្បាយចិត្ត។ មីងនេះកុំថាឡើយខ្ញុំធ្លាប់និយាយលេងជាមួយ សូម្បីតែទិញសាំងគាត់មួយដបណា ក៏ខ្ញុំមិនដែលបានឈប់ទិញសោះ ម៉េចក៏នឹកឃើញមកនិយាយលេងសើចបែបព្រើលៗ?

ខ្ញុំសម្លឹងមុខគាត់ទាំងមុខមាំ ចង់ឱ្យគាត់ដឹងថាខ្ញុំមិនអរជាមួយការលេងសើចគ្មានរបៀបនេះសោះទេ។ ដឹងអីគាត់មិនត្រឹមមិនឈប់ ថែមទាំងនិយាយមកបន្ថែម៖

«បានសង្សារស្អាតដឹកកាត់នេះ មីងលបមើលរាល់តែដង!»

ខ្ញុំគិតថាគាត់រោគចិត្ត។ គិតទាំងកំហឹង ខ្ញុំខ្ជិលតប ក៏ងាកមុខចេញ ហើយអូសម៉ូតូញាប់ជាងមុនសំដៅកុដិ។

ចាក់សោចូលមកដល់ក្នុង ខ្ញុំអស់កម្លាំងនឹងដាំបាយហូបទើបដោះអាវព្យួរ ហើយប្រះមកអង្គុយលើគ្រែសម្រាកកាយចិត្ត។ មិនទាន់ដាក់ខ្នងដល់ក្បាលគ្រែដែលប្រុងថានឹងផ្អែកផង ខ្ញុំបែរជានៅទ្រឹងពាក់កណ្ដាលផ្លូវវិញ ព្រោះក្ដុកចិត្តនឹងរឿងអ្វីមួយ។

«ម៉ែ! យល់សប្ដិឃើញកូនឯងឱបបង្វេចនាំមនុស្សស្រីមកផ្ទះ!» «អន្និតអើយ ថ្ងៃនេះម៉ូតូខូច អត់ដឹកសង្សារមកទេ?»

កែវទឹកបម្រុងនឹងក្រេបនៅទើរត្រង់បបូរមាត់ខ្ញុំ។

«អាសាន់ ថ្មើរម៉ានអ្ហែងម៉ោ? អញមានរឿងចង់ពិភាក្សា!»

ខ្ញុំទាក់ទងទៅអាពួកម៉ាក ព្រោះពេលនេះស្រាប់តែចេះមានអារម្មណ៍ថាខ្លាចបន្ទប់ខ្លួនឯង។ អាសាន់ឆាតមកវិញភ្លាម៖

«អញនៅផឹកជាមួយពួកអារុំ! អ្ហែងម៉ោបាន ម៉ោណេះសិនមក ជុំគ្នាអាថា!»

«អត់ទេ ម៉ូតូអញខូច!»

ខ្ញុំឆ្លើយខ្លី ហើយក្រោកទៅបង្អួច ឈរសម្លឹងពួកក្មេងលេងបាល់ក្រោមអំពូលពងមាន់ក្រហមព្រឿងៗកណ្ដាលទីធ្លាវត្ត។ មេឃងងឹតពេញទំហឹង តែអំពូលពីរនោះអាចធ្វើឱ្យលានបាល់ទះភ្លឺច្បាស់បាន។

ក្នុងភាពងងឹត យើងត្រូវការតែចំណុចភ្លឺខ្លះមក ក៏គ្រប់គ្រាន់ស្រេចហើយ មិនបាច់ច្រើនទេ។ ខ្ញុំសម្រេចចិត្តខ្លួនឯងក្នុងការបញ្ជាក់ពីអ្វីមួយក្នុងពេលនេះ។ ខ្ញុំទាញអាវមកពាក់វិញ ហើយដើរម្នាក់ឯងចេញពីវត្តទៅកាន់តូបលក់សាំងកាច់ជ្រុង។

ក្នុងតូបគាត់ គ្មានអ្វីគួរឱ្យចង់ទិញសោះ។ កូកាមួយកំប៉ុងជាជម្រើសរបស់ខ្ញុំក្នុងការរកលេសនិយាយនឹងមីងនេះ៖

«កូកាមួយមកមីង!»

«យកពីរបីកំប៉ុងទុកហ្មងទៅក្មួយ មេឃស្អុះណាស់!»

«អ៊ីចឹងក៏បាន!»

គាត់រកស្បោងមកច្រកភេសជ្ជៈឱ្យខ្ញុំទាំងញញឹមញញែម៖

បានឱកាសដល់ដៃ ខ្ញុំសួរគាត់ខ្សឹបៗ៖

«មីង! មីងធ្លាប់ឃើញសង្សារខ្ញុំពីអង្កាល់?»

មីងនេះញញឹមមុខក្រហម ហើយឆ្លើយទាំងឱនបារទឹកកក៖

«បើអាអូនឯងដឹកគេកាត់មុខតូបមីងរាល់ល្ងាច រឿងអីមីងមិនឃើញ?»

ខ្ញុំទប់យ៉ាងណា ក៏ខ្ញុំដឹងថាខ្លួនឯងកំពុងវិល?

រកនឹកយ៉ាងណា នៅតែរកនឹកមិនឃើញថាធ្លាប់ដឹកអ្នកណាកាត់នេះឱ្យគាត់យល់ច្រឡំកើតទៅ? អត់មានទេ?

«មីង! មីងឃើញពីអង្កាល់? មីងច្រឡំមនុស្សទេហ្អី?»

មីងងើបមុខមកសម្លក់ខ្ញុំទាំងញញឹម។ ដៃគាត់ហុចស្បោងមក តែខ្ញុំមិនបានចាប់អារម្មណ៍អ្វីក្នុងការទទួលយករបស់ទេ ព្រោះព្រលឹងកំពុងរកកលហោះហើរ ហោះទៅទីផ្សេង។

ត្រចៀកខ្ញុំផ្ទៀងស្ដាប់ចម្លើយគាត់ដែលនិយាយមកខ្សាវៗស្មើសន្ទឹកបេះដូងខ្ញុំដែលលោតជ្រួល៖

«ម្សិលមិញ ក៏មីងឃើញ! ឃើញរាល់ថ្ងៃ!»

ខ្ញុំប្រះរត់ចោលកូកាកូឡាតម្រង់មករកកុដិព្រះចៅអធិការ។ ព្រះអង្គកំពុងតែឆាន់តែក្តៅ និងទូន្មានអាចារ្យប៉ុក និងអាចារ្យសឿន។ ស្ថានភាពរត់ចូលត្រហបរបស់ខ្ញុំធ្វើឱ្យអាចារ្យទាំងពីរញៀកផ្លូវឱ្យសឹងថាមិនទាន់។

ពេលខ្ញុំបានទូលរឿងចប់សព្វគ្រប់ អាចារ្យប៉ុកហាក់ស្លេកស្លាំង ចំណែកអាចារ្យសឿនរៀបចំអុជធូបទៀន។ ព្រះចៅអធិការទាញផ្តិលទឹកដែលមានក្បៀរដៃមក ហើយបង្គាប់ឱ្យអាចារ្យប៉ុកចេញទៅបេះមែកទទឹម។

ខ្ញុំឱនក្បាលទទួលយកពិធីប្រោះព្រំមិននិយាយមិនស្តី តែហោចណាស់ក៏មានភាពកក់ក្តៅឡើងវិញ លែងភិតភ័យស្លោស្លន់ដូចមុន។

«ជួនកាល អ្នកនោះគេស្រវាំងភ្នែក ឬមួយគេមានចិត្តនិយាយបំភ័យ! ត្រឡប់ទៅដេកតាំងចិត្តភាវនាសុំសុខសិរីទៅ! បើញោមមិនធ្លាប់ធ្វើអីអ្នកណា គ្មានអ្នកណាធ្វើអីញោមទេ!»

ព្រះចៅអធិការទូន្មានតិចតួចហើយ ក៏ដេញឱ្យចេញមកដេក។ នៅតាមផ្លូវដើរមកវិញ អាចារ្យសឿនឱ្យចេកខ្ញុំមួយស្និត ហើយផ្កាពីរបីទង ប្រហែលគាត់បេះមកថ្មីៗក្នុងវត្តនេះ។

«ថាឯងដល់បន្ទប់ ចាប់អុជធូប ៣ សរសៃដាក់សែនចេកនេះមាត់ទ្វារ ត្រូវបាចអង្ករមួយដៃលាយអំបិលស្រេច ហើយនិយាយលាគ្នានឹងអ្នកណាក៏ដោយដែលយើងធ្លាប់បានធ្វើខុសលើដោយមិនដឹងខ្លួន! សុំអហោសិកម្មឱ្យចប់រឿង!»

មកដល់បន្ទប់ភ្លាម រាងធូរចិត្តព្រោះឃើញមិត្តម្នាក់ទៀតឈ្មោះដាង លើកសម្លមួយចានមកឱ្យ។

«អាសាន់ខលប្រាប់ថា វាប្រហែលជាយប់ជ្រៅបន្តិច អ៊ីចឹងមិនហ៊ានមកកុដិទេ វាឱ្យដេកមុនទៅ! ហើយណេះសម្ល ឯងស្លខ្លួនឯង ឆ្ងាញ់មិនឆ្ងាញ់ កុំថាអីវ៉ី!»

ខ្ញុំបានឱកាសក៏និយាយសារភាពប្រាប់ដាងសព្វគ្រប់បែបយ៉ាង ហើយសុំដាងឱ្យនៅគេងកំដរ។ ក្នុងចិត្តគិតថាស្អែកនឹងឡើងទៅស្រុកសិន សុខចិត្តខានរៀនពីរបីថ្ងៃ។

ដាងយល់ការណ៍ក៏រើខ្នើយមកគេងកំដរខ្ញុំមែន។ ចំណែកតាសឿន មុនពេលចេញទៅវិញ គាត់ប្រាប់ថា ភ្លឺម៉ោង ៦ ព្រឹក គាត់នឹងមកជូនខ្ញុំទៅរកអាចារ្យម្នាក់នៅវត្តផ្សេងទៀតឈ្មោះតាសច្ចា តានោះជាអ្នកចូលរូបបាន ហើយអាចមានញាណដឹងអ្វីៗក្នុងផ្លូវងងឹត ក្រែងអាចជួយរកដំណើរដើមទងឃើញមុនពេលវិលទៅស្រុកដោះស្រាយ។

ដាងជាអ្នកស្រុកបន្ទាយមានជ័យ។ គេហាក់មានជំនឿលើគ្រប់អ្វីដែលខ្ញុំជួប ហើយគាំទ្រឱ្យខ្ញុំទៅជាមួយតាសឿនសិន សឹមវិលទៅផ្ទះដោះស្រាយជាក្រោយ។

យប់ម៉ោងប្រហែល ៩ គេដេកលើគ្រែអាសាន់ ហើយខ្ញុំដេកលើគ្រែខ្លួនឯង តែមិនបានចងមុងទេ ព្រោះមានរឿងជជែកគ្នាចុះឡើងមិនឈប់។

«រកនឹកមើល៍ ថាឯងធ្លាប់ទៅធ្វើអីប៉ះពាល់គេ ហើយភ្លេចខ្លួនដែរអត់?»

ពេលដាងសួរអ៊ីចឹង ខ្ញុំដេកគងថ្ងាសគិត។ ខ្ញុំមិនដែលខ្វល់រឿងអ៊ីចឹងៗ ហើយក៏មិនដែលធ្លាប់បានធ្វើរឿងក្បត់ចិត្តធ្វើបាបមនុស្សស្រីណាម្នាក់ដែរ។

«មានអារម្មណ៍ថាមួយរយៈនេះ ខ្ញុំស៊យដល់ហើយ ដាង! ឧស្សាហ៍មានរឿងប្លែកៗ ឮសូរប្លែកៗ គ្រាន់តែមិនដែលឃើញផ្ទាល់! អុះមែនហើយដាង កាលពីទៅការប្អូនរបស់សារុំ ខ្ញុំងើបទៅនោមកណ្ដាលយប់ ក៏ឃើញមនុស្សស្រីឈរច្បាស់ថៃសទាំងដែលនៅផ្ទះហ្នុងគ្មានអ្នកណានៅផង មានតែគ្នាយើងប្រុសៗប៉ុន្មាននាក់! យប់មិញ ដេកនៅផ្ទះដារិទ្ធពួកម៉ាករបស់អាសាន់ គេងបីនាក់គ្មានអ្នកណាឮអី ឮតែឯងឯណេះម្នាក់ឯង!»

«ថាឯងឮស្អីគេ?» ដាងសួរទាំងបារម្ភ។

«ខ្ញុំឮមនុស្សស្រីក្អកគ្រហែមមិនឈប់! ឮស្នូរជើងត្រកួតក្នុងបន្ទប់ទឹកឡើងសង្កៀរត្រចៀក! ទ្រាំមិនបាន ខ្ញុំក៏ក្រោកទៅមើល តែដាងឯងមើល អត់ឃើញអីទាំងអស់!»

ដាងចាប់ផ្ដើមស្ញាប ហើយបញ្ជាប់ខ្ញុំ៖

«អើដេកសិន ភ្លឺឡើងចាំដោះស្រាយ! មិនអីទេ បើខ្លាចស្រែកហៅខ្ញុំ!»

ដាងដេកស្ងៀម ខ្ញុំក៏លែងហ៊ាននិយាយរំខាន តែចិត្តខ្ញុំគិតបែកមែកធាងទៅដល់រឿងជាច្រើន។

«ខ្ញុំខ្លាចណាស់! ហើយខ្ញុំមិនដែលមានរឿងជាមួយទេ កុំមកលងខ្ញុំទៀត!»

ខ្ញុំទន្ទេញពាក្យនេះក្នុងចិត្តខ្លួនឯងរហូតដល់លង់លក់ទាំងទុក្ខកង្វល់។

ក្នុងសុបិន ខ្ញុំយល់សប្ដិឃើញនៅកន្លែងថ្មីមួយ ហើយវាជាពេលយប់។ អ្នករាល់គ្នាកំពុងដេកលក់ស្ងាត់ស្ងៀម សល់តែខ្ញុំដែលពោរពេញទៅដោយអារម្មណ៍ភ័យខ្លាច។ ភ្លាមៗនោះ ស្នូរគោះទ្វារបានលាន់ឮមកគួរឱ្យរន្ធត់ចិត្ត។ ផ្ទៀងស្ដាប់យ៉ាងណា វានៅតែលាន់ឮមកពីខាងក្រៅបន្ទប់។ ក្នុងយល់សប្ដិនោះ ខ្ញុំឃើញខ្លួនឯងក្រោកឡើងទៅបើកទ្វារទាំងនឹកឆ្ងល់ថាតើនរណាទៅមកគោះទ្វារថ្មើរណេះ?

ទ្វាររបើក ខ្ញុំស្រាប់តែឃើញនារីម្នាក់ដែលខ្ញុំមិនស្គាល់មិនចំណាំ ហើយឈរបែរខ្នងក្រោមដើមឈើធំមួយត្រឈឹងត្រឈៃ។

ខ្ញុំចង់ហាមាត់សួរនាងអំពីហេតុផលដែលមកគោះទ្វារ តែមាត់ខ្ញុំ បំពង់កខ្ញុំដូចជាស្លាក់និយាយមិនចេញ ហាមិនរួច បានត្រឹមង៉ុលៗ។

ក្នុងអារម្មណ៍ ខ្ញុំគិតថានាងជាខ្មោច ដៃជើងខ្ញុំភ័យ តែរើខ្លួនមិនរួច។

ខ្ញុំសូត្រធម៌បួងសួងម្នាក់ឯងឱ្យរូបនាងរលាយបាត់ទៅ សូត្រញាប់ឡើងៗ ស្រាប់តែនាងងាកមកយឺតៗធ្វើឱ្យបេះដូងខ្ញុំចង់គាំង។

ធម៌ក៏លែងបានសូត្រ គ្រប់យ៉ាងគាំងផ្អឹង នៅតែដង្ហើមដ៏ហត់របស់ខ្ញុំ។

វាពិតជាអារម្មណ៍ដ៏ចម្លែកដែលនាងមិនបានហើបមាត់ តែខ្ញុំហាក់យល់ពីអ្វីដែលនាងចង់និយាយ។

«ជួយរកកូនខ្ញុំផង!»

បរិយាកាសគឺចម្លែក ហើយមានភាពតានតឹង។ ខ្ញុំស្រែកវ៉ាស ព្រោះនាងខ្មៅអ៊ូញ គ្មានមុខទេ គឺងងឹតស្លុប។

ដឹងខ្លួនមក បែកញើសស្អិតដៃជើង។ ទ្រនិចនាឡិកាចុងជើងចង្អុលត្រឹមម៉ោង ២ គត់ ហើយដាងវិញក្រោកមកអង្គុយទាំងទឹកមុខងងុយ។ ប្រហែលជាខ្ញុំស្រែកឮពេកហើយ ធ្វើឱ្យភ្ញាក់ដល់គេ។

គេនោះក្រោកទៅបើកភ្លើង។

«បើកភ្លើងដេក ម៉េចដែរ?»

គេទំនងជាយល់ពីស្ថានភាពរបស់ខ្ញុំ បានជាមិនព្រមសួរនាំ ហើយនិយាយយ៉ាងដូច្នេះកាត់សេចក្ដីតែម្ដង។ ខ្ញុំមិននិយាយអ្វីទៀត ក្រៅតែពីងក់ក្បាល ឯដៃម្ខាងរាវរកក្រមាមកជូតសម្អាតញើស។

ដំបូងខ្ញុំភ័យខ្លាច គិតចុះឡើងពីយល់សប្តិមួយប្រាវនោះ ប៉ុន្តែក្រោយមកបន្តិចខ្ញុំលង់លក់សាជាថ្មីទៀតរហូតដល់ដឹងខ្លួនមកវិញមេឃភ្លឺចែស។

ដាងនៅមាត់ទ្វារកំពុងអង្គុយមើលក្មេងរត់លេង។ អាសាន់មកដល់ វាឈប់ម៉ូតូ ហើយអើតរកខ្ញុំ។

«មុជទឹកនៅអ្ហែង? តោះ អញដឹកទៅជួបតាសឿន!»

ខ្ញុំមិនមាត់មិនក ព្រោះហត់ណាស់រាងកាយទាំងមូលឡើងល្វើយ។ ដេកដូចមិនបានដេក។

ខ្ញុំដឹងថា តាសឿននឹងនាំខ្ញុំទៅជួបអាចារ្យម្នាក់ដែលគាត់ស្គាល់។

«អញយល់សប្តិឃើញស្រីម្នាក់មកគោះទ្វារទៀតហើយ! អញជិតឆ្កួតហើយ!»

ខ្ញុំនិយាយបែបនេះទៅរកអាសាន់ ពេលចេញពីបន្ទប់ទឹកមកវិញ។

ដាងខំនិយាយលើកទឹកចិត្តខ្ញុំថា៖

«កុំគិតពេក គង់តែដោះស្រាយបានទេ!»

ដាងទៅបន្ទប់វិញ ខ្ញុំអរគុណគាត់។ ចំណែកអាសាន់ធ្វើមុខស្រពោន អង្គុយអត់ធ្មត់រង់ចាំខ្ញុំសិតសក់រួចនឹងអាលឱបទៅ។ តាមផ្លូវទៅរកតាសឿន យើងមិនបាននិយាយអ្វីទៀតទេ។

## វត្ត

## តាសច្ចា

ដូចពាក្យណាត់ តាសឿនរង់ចាំខ្ញុំជាស្រេចជាមួយផ្លែឈើ និងផ្កាក្នុងដៃ។ គាត់ឡើងម៉ូតូពីក្រោយខ្ញុំ ហើយពួកយើងចេញដំណើរ។

«ខ្ញុំយល់សប្តិឃើញស្រីម្នាក់! គេគ្មានមុខទេ! ខ្មៅងងឹត! គេឱ្យខ្ញុំជួយរកកូនគេ!»

តើខ្ញុំអាចភ្លេចបានទេនូវសម្តីខ្លីៗដែលគេមានក្នុងសុបិនគួរឱ្យខ្លាចនោះ?

យើងដឹងថាអ្វីមួយដែលគួរឱ្យរន្ធត់បានកើតមាន តែគ្មានអ្នកណាតបនឹងសម្តីខ្ញុំទេ។ តាសឿនបង្គាប់ទៅអាសាន់៖

«បត់ស្តាំ ហើយទៅត្រង់ទៅ!»

តើខ្ញុំបានធ្វើខុសលើអ្នកណា? ខ្ញុំគិតបែបនេះតែម្នាក់ឯងមួយចប់តាមផ្លូវ។ ចុងក្រោយ គាត់ហៅឱ្យអាសាន់ឈប់ម៉ូតូ។ ពេលនេះដល់វេនអាសាន់ វាហើបមាត់សួរម្តង៖

«ក្រែងថាជូនវាទៅវត្តហ្អីអ៊ំ?»

ខ្ញុំងើបមុខសម្លឹង។ នេះគឺជាបរិវេណផ្ទះល្វែងចាស់ៗសល់មកពីសម័យអាណានិគម។

ទោះបីជាខ្ញុំមកស្នាក់នៅភ្នំពេញយូរហើយ តែតំបន់នេះចម្លែកសម្រាប់ខ្ញុំដែរ ព្រោះមើលទៅ វាហាក់ត្រូវបានហ៊ុមព័ទ្ធដោយសំរាម និងដីវាលធំមួយដែលទំនងត្រូវបានគេទិញទុកមិនទាន់សង់អ្វីនៅឡើយ បានជាស្មៅដុះវែងៗ ហើយឮសំឡេងសត្វយំ។

«គាត់មិនស្រួលខ្លួន កូនគាត់យកមកសម្រាកផ្ទះ! មិនទាន់ត្រឡប់ទៅវត្តវិញទេ!»

តាសឿនឆ្លើយ ហើយក៏នាំផ្លូវខ្ញុំឡើងទៅរកជណ្ដើររងងឹតមួយ។ អាសាន់វានៅរកកន្លែងទុកម៉ូតូ ទំនងវាមិនបានឡើងមកទេ។

ដូច្នេះខ្ញុំក៏សួរ៖

«អ៊ំ! គាត់មិនស្រួលខ្លួនផង យើងមករកគាត់ធ្វើអី?»

តាសឿនមិនមាត់ គាត់អូសដៃខ្ញុំឡើងដល់ជាន់ទីមួយ។ នេះជាអគារវែងអន្លាយ ហើយកខ្វក់។ ព្រះអាទិត្យចាំងមកបានតិចតួច ហើយផ្ទះនីមួយៗបិទទ្វារជិតឈឹង ទំនងជាមកពីបរិយាកាសខាងក្រៅមិនល្អ បានជាគេមិនចេញមកអង្គុយលេង។

ពេលនេះទើបតាសឿនឱនមកខ្សឹបប្រាប់៖

«យប់មិញ អ៊ំតែមកគាត់មុន! គាត់អង្គុយបិទភ្នែកក៏ឃើញមានខ្មោចស្រីមួយតាមឯងរហូតមែន!»

ខ្ញុំក្ដុកក្នុងចិត្ត តែទ្រាំអត់ធន់មិននិយាយកាត់គាត់ទេ។ តាសឿននិយាយបន្ថែម៖

«ឯងត្រូវប្រញាប់ឱ្យគាត់ធ្វើពិធីរកហេតុផល! កុំភ័យតារៀបចំគ្រឿងដង្វាយមកហើយ ស្លាម្លូមានទាំងអស់!»

«ចាំខ្ញុំជូនលុយអ៊ំសរុបហ្មង!»

ខ្ញុំនិយាយតបទាំងពិបាកចិត្ត ចំណែកគាត់វិញឈប់និយាយ ហើយដៃលើកមកអង្អែលស្មាខ្ញុំ។

យើងឡើងមកដល់ជាន់ទីពីរ។ វាភ្លឺជាងខាងក្រោមបន្តិច តែគាត់ងើយសម្លឹងទៅហាក់ចង់ប្រាប់ខ្ញុំថាអាចារ្យនោះស្នាក់នៅជាន់ខាងលើទៀត។ នៅខាងលើមានផ្ទះល្វែងតិចជាងជាន់ក្រោមៗ។ ផ្ទះអាចារ្យសថ្លានៅចំមាត់ច្រកជណ្ដើរឡើងតែម្ដង ហើយគាត់បើកទ្វាររង់ចាំយើងជាស្រេច។

មួយក្រឡេកសំដៅទៅក្នុងផ្ទះ ខ្ញុំប្រទះភ្នែកនឹងកៅអីបង្អែកបែបខ្មែរដែលធ្វើពីឈើ និងមានច្រើនបន្ទះអាចប៉ាក់ប៉ើកចុះឡើងបាន។

«ចូលមកសឿនអើយ!»

សំឡេងតាចាស់ម្នាក់លាន់ចេញមកហាក់ដូចចង់បញ្ជាក់ថាគាត់កំពុងមានវត្តមាននៅក្នុងផ្ទះ ហើយពួកយើងអាចចូលបាន។

បន្ទាប់ពីដោះស្បែកជើងរួច ខ្ញុំចូលតាមតាសឿនដល់ខាងក្នុង។ តាសច្ចាមានចំណាស់ប្រដំត្រសង នឹងជីតារបស់ខ្ញុំនៅស្រុក។ គឺគាត់ចាស់ជាងតាសឿនដែលនាំខ្ញុំមក។

គាត់ពាក់អាវសដៃវែងរាងជំនំ ហើយអង្គុយបត់ជើងលើគ្រែក្ដារស្មៀជាមួយនឹងគ្រឿងពិធីមានទៀនធូប រង់ចាំខ្ញុំជាស្រេច។ វាគឺជាគ្រែស្រឡៅដ៏ធំមួយនៅចំកណ្ដាលបន្ទប់។ គាត់ទំនងជានៅទីនេះម្នាក់ឯង គ្មានអ្នកផ្សេងទេ។ អ៊ីចឹងក៏ល្អ ខ្ញុំមិនសូវបែកអារម្មណ៍។

«ក្មេងនេះហើយ! យប់មិញគ្នាយល់សប្តិឃើញទៀត គេមកប្រាប់ថា ឱ្យជួយរកកូនគេ!»

តាសច្ចាងក់ក្បាល ហើយឱ្យសញ្ញាទៅតាសឿន។ គាត់ចាប់ផ្តើមទាញថាសរៀបចំផ្លែឈើ និងផ្កាដាក់ក្បែរតាសច្ចា។ កាយវិការទាំងនេះធ្វើឱ្យខ្ញុំនឹកឃើញភ្លាមៗដល់បទពិសោធកាលខ្ញុំអង្គុយមើលគេរៀបពិធីបរព្រៃនៅឯស្រុក។

គាត់ទាំងពីរឱ្យខ្ញុំឡើងអង្គុយបត់ជើងចំពីមុខគ្រែ ហើយលើកដៃប្រណមបិទភ្នែកទាំងសង។

ក្នុងពេលប្រមាណមួយនាទីដែលគេកេះដែកភ្លើងអុជធូបធុំក្លិនឆួល ខ្ញុំឮតាសច្ចាទន្ទេញធម៌ញាប់ស្មេ ហើយនិយាយភាសាអ្វីដូចពួកកូនក្មេងជជែកគ្នាស្តាប់មិនបាន។

បទពិសោធមួយនេះធ្វើឱ្យខ្ញុំកាន់តែវិលវល់ចិត្តនឹកថាហេតុអ្វីខ្លួនឯងត្រូវមកធ្លាក់ក្នុងរឿងរ៉ាវអស់ទាំងនេះ?

«រកឃើញហើយ!»

គាត់ភ្លាត់មាត់និយាយឮៗធ្វើឱ្យខ្ញុំបើកភ្នែកមកវិញ។

«អាចៅនេះ ថ្មីនេះវាភ្លាត់ទៅដើរក្រោមស្នួខោអាវអ្នកដែលគេកំពុងអាប់រាសីឈឺធ្ងន់! ហើយវាមានក្លិនសាច់ឆ្កែក្នុងខ្លួនទៀត ទើបខ្មោចអាចមកយាយីអុកឡុកបាន!»

«ខ្ញុំមិនដែលហូបសាច់ឆ្កែទេ!»

ខ្ញុំតវ៉ាទាំងព្រួយបារម្ភ ប៉ុន្តែតាសឿនកេះខ្ញុំពន្យល់មួបៗ៖

«ស្តាប់សិនទៅ!»

ពេលខ្ញុំនៅអង្គុយបត់ជើងលើកដៃប្រណមបន្ត តាម្ចាស់ផ្ទះនិយាយប្រាប់ខ្ញុំមួយៗ៖

«អន្ទិតឯង ស្តាប់តាឱ្យទាន់! ចេញពីនេះ ត្រូវស្រូតទៅផ្ទះរកម្តាយឱ្យធ្វើពិធីឱ្យ! តារកឃើញមូលហេតុដែលខ្មោចនោះតាមឯងមក តែតាមិនអាចធ្វើអ្វីបាន ដោយសារតាឈឺមិនអាចសង្រួមអង្គុយភាវនាឱ្យបានយូរ! ឯងមានខ្មោចព្រាយមកតាមបាន ដោយសារឯងនៅចំកន្លែងពិធីដែលគេដាស់ព្រាយ ហើយរាសីថៅឯងខ្សោយ ដោយសារមានក្លិនសាច់ឆ្កែ និងដើរក្រោមស្នួដូចតាបានប្រាប់! គេឱ្យឯងជួយអ្វី ត្រូវពិគ្រោះនឹងគ្រូណាដែលគាត់ចេះពិត! មិនអីទេ គេអាចធ្វើឱ្យព្រាយនោះទៅរហូតបាន!»

ខ្ញុំនៅតែនឹកមិនឃើញទេថាហូបសាច់ឆ្កែពីពេលណា ប៉ុន្តែនេះគឺជាបទពិសោធថ្មីគួរឱ្យរន្ធត់ណាស់សម្រាប់ខ្ញុំ។ ព្រាយស្អីទៅ?

ដឹងថានេះជាការរកឃើញដែលកំពុងធ្វើឱ្យខ្ញុំភ្ញាក់ផ្អើល តាសៀនលូកមាត់មកពន្យល់៖

«រឿងសាច់ឆ្កែ ជួនកាលពួកម៉ាកលួចដាក់ពេលផឹកស៊ីមិនប្រយ័ត្ន! ថ្ងៃក្រោយ ចន្លាឯងត្រូវប្រយ័ត្ន យើងអ្នកមានញាតិតាមថែរក្សា ត្រូវនឹងសាច់អស់ហ្នឹង ដឹងតែមានរឿងភ្លាម ព្រោះដូនតាខឹងនៅមិនបាន!»

«ព្រាយស្អីទៅ? ខ្ញុំមិនដែលធ្វើអីផ្តេសផ្តាសទេ! ហេតុអីមានគេឃើញខ្ញុំឱបមនុស្សស្រី?»

តាសច្វាក្រេបតែរបស់គាត់ ហើយនិយាយពន្យល់ខ្ញុំ៖

«ជួនកាល ខ្លួនយើងមើលមិនឃើញ តែអ្នកដទៃគេមើលឃើញ! ព្រាយនោះតាមមកប្រហែលមានអ្វីឱ្យថៅឯងជួយគេ ចំណែកមកពីណា ទាល់តែតាបិទភ្នែកសួរសិន!»

ខ្ញុំមិនជឿលើសម្តីទាំងនេះទេ គឺមិនជឿទាំងស្រុង។ ចិត្តមួយខ្ញុំប្រុងថាបដិសេធ ហើយចាកចេញ ប៉ុន្តែចិត្តមួយចង់ដឹងថាគាត់នឹងនិយាយអំពីអ្វីទៀត។ រឿងទៅផ្ទះរកម៉ែពិគ្រោះ ខ្ញុំគង់តែទៅទេ ប៉ុន្តែខ្ញុំឆ្ងល់ថាតានេះចេះមើលតែមិនចេះដោះ តើមករកគាត់មានន័យដែរ?

«ព្រាយនោះចេញមកពីដើមឈើធំមួយ!»

ខ្ញុំភ្ញាក់ក្រញាង នឹកឃើញដល់រូបរាងដើមឈើដែលខ្ញុំបានឃើញក្នុងសុបិនកាលពីយប់មិញ។

«អន្ទិតឯងមានដែលទៅមើលគេធ្វើពិធីអីអត់ទេ?»

ខ្ញុំចាប់ផ្តើមនឹកសង្ស័យ។ ត្រូវហើយ ទើបនឹងចាប់អារម្មណ៍ឃើញថាដើមឈើដែលបានឃើញកាលពីយប់មិញ និងដើមឈើដែលបងឌីនទាញរំលំ គឺជារូបតែមួយ។

«បាទតា! ខ្ញុំបានមើលគេដករំលំឈើកាលពីប្រហែលមួយខែមុន!»

ខ្ញុំភ្លាត់មាត់ឆ្លើយទាំងស្លុងចិត្ត។ ស្រាប់តែតាសច្ចាសួរវិញភ្លែត៖

«គេមានធ្វើពិធីបរព្រៃអីដែរទេ?»

ខ្ញុំបើកភ្នែកធំៗមិនទាន់នឹកឃើញថាត្រូវឆ្លើយបែបណាផង ស្រាប់តែតាសច្ចានិយាយមកបន្ថែម៖

«បើពេលនោះគេកំពុងធ្វើបរព្រៃហៅអស់ពួកព្រាយបិសាចដែលទំនៅលើនោះឱ្យហើរចេញ វាអាចនឹងនាំទុក្ខឱ្យពួកនោះតាមមកជាមួយមនុស្សណាដែលមានរាសីទាបៗ! យើងមិនគួរទៅអង្គុយមើលគេទេ បើយើងស្ថិតក្នុងពេលវេលាដែលដាក់ ដូចជាអន្ទិតឯងនេះមិនគួរទៅសោះ ព្រោះដួនតាកំពុងខឹង!»

ខ្ញុំប្រហែលជាស្លេកស្លាំងពេកហើយ បានជាគាត់ចងអំបោះក្រហមឱ្យមួយ ហើយផ្តាំ៖

«ទៅរកចាស់ៗគិតគ្នាសិនទៅ! បើទៅរកបានគ្រូដែលគេចេះធ្វើបរព្រៃនោះទៀត ឱ្យជួយបណ្តេញព្រាយកាន់តែល្អ! ប្រាប់គេរឿងរ៉ាវអស់នេះទៅ គេដឹងថាត្រូវដោះអាម៉េច! មួយទៀត អន្ទិតឯងក៏កុំភ័យអីពេក ព្រាយនោះប្រហែលមិនមែនចង់ធ្វើបាបអន្ទិតឯងទេ គ្រាន់តែថាបើយើងទុកទៀត វាមិនសូវល្អ!»

ខ្ញុំស្រាប់តែនឹកឃើញឡើងវិញ ស្វាងថៃសដូចថ្ងៃ។

សម្តីតាសច្ចាក៏មិនមែនថាគ្មានហេតុផលនោះដែរ។ ចាប់តាំងពីចូលរួមអង្គុយមើលពិធីបរព្រៃនៅឯស្រុករួច ខ្ញុំពិតជាជួបរឿងចម្លែកៗគួរឱ្យកត់សម្គាល់មែន។ ខ្ញុំនឹកឃើញឡើងវិញដល់កាលពីទៅការប្អូនម្នាក់ឈ្មោះសារុំ។

នៅពេលក្រោកទៅបន្ទប់ទឹក ខ្ញុំពិតជាឃើញមនុស្សស្រីឈរក្នុងកន្លែងងងឹត ហើយអ្នកផ្សេងក៏គេថាឃើញដូចខ្ញុំដែរទាំងដែលផ្ទះនោះមិនដែលមានអ្នកណានៅសោះ?

តើពិតជាព្រាយដើមឈើដដែលៗនោះតាមមកមែន បានជាចេះតែមានរឿងអស់នេះ? ពិសេសក្នុងបន្ទប់ជួលរបស់ដារិទ្ធ ពិតជាមានដៃស្រីមកស្ទាបអង្អែលខ្ញុំពិតមែន តែគ្មានអ្នកណាសោះពេលព្រឹកឡើង។ ម៉ែខ្ញុំនៅសុខៗយល់សប្តិឃើញខ្ញុំឱបបង្វេចនាំស្រីម្នាក់ទៅផ្ទះទៀត? ចំណែកអ្វីដែលមីងលក់សាំងឃើញ ក៏កាន់តែហួសនិយាយ។

«តោះ ស្រួតទៅរកមធ្យោបាយ!»

តាសឿនកេះហៅខ្ញុំឱ្យលាម្ចាស់ផ្ទះចេញមក។

ពេលចុះដណ្ដើរមក តាសឿនឆ្លៀតដេញដោលសួរខ្ញុំ៖

«ចន្លាឯងធ្លាប់មានប្រវត្តិកាប់រំលំឈើប៉ុន្មានលើកហើយ?»

«អត់ទេអ៊ំ! ពុកខ្ញុំបានគាត់ធ្វើមែន! អាថ្ងៃហ្នុង ខ្ញុំទៅលេងផ្ទះ ទំនេរៗពុកបបួល ខ្ញុំក៏ទៅមើលគេលេងទៅ!»

គាត់នៅស្ងៀម ខ្ញុំក៏ធុញថប់ស្មុគចិត្តពេករអ៊ូនឹងគាត់៖

«មនុស្សនៅកន្លែងពិធីមួយគគោក មិនទៅរក មករកអីខ្ញុំហ្នឹង?»

តាសឿនដង្ហើមធំទះស្មាខ្ញុំមួយៗ ហើយនិយាយប្រាប់វិញ៖

«នៅខាងលើ ក្រែងគាត់ប្រាប់រួចហើយ! យើងនេះរាសីទាប! មិនគួរទៅមើលគេធ្វើពិធីដេញព្រាយខ្មោចអីទេ! ហើយរឿងដើមឈើនេះ ចាស់គាត់ប្រកាន់ណាស់! មុនកាប់រំលំ គេមានពិធីមានអីច្រើនបែបច្រើនយ៉ាងបានគេហ៊ានធ្វើ! នៅស្រុកអ៊ំ មានប៉ិមួយនោះគាត់មិនបានស៊ីឈ្នួលកាប់ឈើឱ្យអ្នកណាទេ ប៉ុន្តែកូនស្រីការ គាត់ជឿជំនឿថា ដើមអំពិលខាងត្បូងផ្ទះមិនល្អ ដោយត្រូវវានដីសង់ផ្ទះថ្មីឱ្យកូនគាត់ ក៏អុជធូប ហើយកាប់ដើមអំពិលចោល។ ជិតរួចរាល់ហើយហ្នឹង ចង្រៃអី មែកវាសល់អាចុងក្រោយមួយទំហំតូចប៉ុនស្មងជើង បាក់មកភីស ភ្លាត់មកបុកចំទទឹងខ្លួនមនុស្សដាច់ខ្យល់គ្មានបាននៅការកូនទេ! នេះមិនឱ្យអ្នកស្រុកជឿម៉េចបាន?»

ខ្ញុំនៅស្ងៀម ហើយទទួលអារម្មណ៍ថាត្រជាក់ចុងដៃជើងភ្លាមៗដែរ។ មកដល់ក្រោម គាត់ឆ្លៀតផ្ដាំ៖

«ដោះអំពើព្រាយអីអស់នេះ ទាល់តែរកគេអ្នកចេះខាងហ្នុងបានវាស័ក្ដិសិទ្ធ! យកល្អ ឆាប់ទៅរកម្ដាយឱ្យគាត់រកគេទៅ! នៅកន្លែងដែលចន្លាឯងទៅឃើញគេបរព្រៃនោះ ប្រាកដជាមានគេដែលមានថ្វីដៃដឹងថាដោះស្រាយរបៀបម៉េច!»

ចេញពីផ្ទះតាសច្ចាមកតាមផ្លូវ ចិត្តខ្ញុំរញ៉េរញ៉ៃនៅមិនសុខមិនសាប់។ ដាច់ខាត ខ្ញុំតាំងចិត្តថាត្រូវបកទៅស្រុកភ្លាមៗ ដោយមានអាសាន់ជាអ្នកឌុបទៅ ចំណែកតាសឿនវិញ គាត់មិនបានមកជាមួយយើងទេ។

ម្ដាយខ្ញុំវិញគ្រាន់តែឃើញខ្ញុំមកដល់ ក៏មិនបានសួរខ្ញុំអ្វីទាំងអស់ គាត់បានលូកដៃមកទាញខ្ញុំទៅខ្សឹបក្នុងបន្ទប់៖

«ព្រលឹមស្អែក យើងចេញទៅរកតាជន្ទល់ខ្មៅ!»

ខ្ញុំមិនដឹងទេថាតាជន្ទល់ខ្មៅជាអ្នកណា តែខ្ញុំក៏មិនខ្វល់ដែរ អ្នកណាក៏ដោយឱ្យតែអាចដោះស្រាយបញ្ហាឧបទ្រពឱ្យខ្ញុំក្នុងពេលនេះបាន ខ្ញុំទៅទាំងអស់។

តាំងពីបុរាណមក គ្រូទាយ ឬគ្រូផ្លូវងងឹតនានាមានឥទ្ធិពលយ៉ាងខ្លាំងមកលើភូមិស្រុករបស់ខ្ញុំ ដោយឡែកពុកម៉ែខ្ញុំក៏ដូចគ្នា។ ខ្ញុំមិនដឹងម្ដាយពេលទទួលបានដំណឹងរបស់ខ្ញុំ ឪពុកម្ដាយខ្ញុំទៅរកគ្រូដល់ណាឱ្យទាយថាយ៉ាងណាខ្លះទេ តែខ្ញុំធុំក្លិនធូបពេញតែផ្ទះ។

មុនមេឃងងឹត ម្ដាយខ្ញុំបានហៅខ្ញុំឱ្យទទួលការស្រោចទឹកក្រោមផ្ទះដែលធ្វើដោយគាត់ផ្ទាល់  ចំណែកពុកសូត្រធម៌រងំពីជាន់ខាងលើ។

ដោយសារតែការអស់កម្លាំងដ៏ខ្លាំងក្លា ឥទ្ធិពលពីផ្លូវចិត្ត និងការធ្វើដំណើរ ខ្ញុំបានសម្រេចចិត្តដេកលក់មួយភាំងនៅក្នុងបន្ទប់ភ្ញៀវទាំងទូរទស្សន៍បើកចោល។

នៅខាងក្រៅ កូនជាងរបស់ពុកខ្ញុំនិយាយគ្នាលេងសើចឡូឡាពេលបរិភោគអាហារ ហើយម៉ែហៅខ្ញុំច្រើនដង ខ្ញុំនៅតែក្រោកមិនរួចសោះ។

ពេលកំពុងគេង ខ្ញុំមានអារម្មណ៍ថាខ្ញុំដឹងឮអ្វីគ្រប់យ៉ាង គ្រាន់តែហត់ពេក ចង់សំងំថែមបន្តិចហើយបន្តិចទៀត។ ខ្ញុំថែមទាំងដឹងទៀតថា ថ្មើរណេះ បើគេងស៊ុបទៅ ងាយនឹងត្រូវខ្មោចសង្កត់ទៀតណាស់ ប៉ុន្តែចុងក្រោយទៅ ទោះដឹងអ្វីជុំវិញខ្លួនពាក់កណ្ដាល តែខ្ញុំចាប់ផ្ដើមរើលែងបាន និយាយលែងរួចមែន។

សំឡេងបងឪន និងកូនជាងផ្សេងៗរសាត់កាន់តែឆ្ងាយទៅៗ ជំនួសមកវិញនូវសូរបំពេកូនរបស់អ្នកណាម្នាក់។

«ខ្មោចលងខ្ញុំហើយ!»

ខ្ញុំប្រាប់ខ្លួនឯងយ៉ាងភ្លីស្មាង ហើយខំបើកភ្នែកខ្វាច់។ គ្រប់យ៉ាងងងឹតស្រពេចស្រពិល។ ខ្ញុំសម្គាល់កន្លែងនេះយ៉ាងលំបាក និងយឺតៗ។

ខ្ញុំឃើញពុកម៉ែកំពុងអង្គុយបែរខ្នងមើលទូរទស្សន៍ តែខ្ញុំហៅគាត់មិនឮសោះ មាត់ខ្ញុំនិយាយម្លូបៗ ខំយ៉ាងណាក៏ហាមិនបាន ចុងដៃចុងជើងល្ងើយដូចខ្យល់។ ខ្ញុំឃើញខ្លួនឯងដើរ ប៉ុន្តែខ្ញុំបញ្ជាទិសដែលត្រូវឆ្ពោះទៅមិនបានសោះ។

អ្នកណាម្នាក់ជាមនុស្សស្រីហាក់នៅកន្លែងណាមួយដែលខ្ញុំមើលពុំឃើញ ហើយគាត់ព្យាយាមនិយាយមកកាន់ខ្ញុំ។

ខ្ញុំផ្ទៀងណាស់ដើម្បីស្ដាប់អ្វីដែលនាងកំពុងនិយាយមកទាំងដែលរាងកាយខ្លួនឯងត្រូវប៉ើងស្រាលស្ទើកចេញទៅបណ្ដើរៗទប់មិនជាប់។ ពីខាងក្រៅផ្ទះ សូរសំឡេងច្រៀងបំពេកូន បានប្ដូរមកជាភ្លេងបុរាណយ៉ាងតម្លូញ ប៉ុន្តែពេលផ្ទៀងស្ដាប់ឱ្យជិតដល់ទៅ បានក្លាយទៅជាសំឡេងមនុស្សស្រីយំខ្សោយៗ។

«ជួយរកកូនខ្ញុំផង!»

ខ្មោចស្រីបាត់កូន ខ្ញុំធ្លាប់តែឮក្នុងនិទានកថាចាស់ៗកាលពីនៅក្មេងៗ តែពេលនេះដែលអាក្រក់ជាងការគិត គឺសំឡេងរបស់នាងដែលស្រែកមកលន្លង់លន្លោចហាក់ប្រាប់ខ្ញុំភ្លាមថា នាងមិនមែនជាមនុស្សទេ។ ជួនកាល សំឡេងនាងស្រែកមកនៅក្បែរត្រចៀក ហើយមួយប៉ប្រិចភ្នែកទៀត សំឡេងរបស់នាងស្រាប់តែស្ងប់ស្ងាត់រលត់ឈឹង រួចទើបលាន់មកពីចម្ងាយមិនស្គាល់ទិសវិញ។

«កូនខ្លួននៅឯណា ម៉េចមកសួរខ្ញុំ ខ្ញុំម៉េចដឹង?»

ភ្ញាក់ផ្អើលណាស់ដែរ ដែលខ្លួនឯងស្រាប់តែអាចនិយាយចេញ ហើយនិយាយដូចជាបានខំប្រឹងទប់ប្រយោគនេះជាយូរមកហើយ។

«រកកូនឱ្យខ្ញុំផង!»

នាងនិយាយពាក្យនេះទៀត ហើយបង្ហាញខ្លួននៅពីមុខខ្ញុំចម្ងាយប្រមាណជា ១០ ម៉ែត្រ។ ក្រោមពន្លឺភ្លឺព្រាលៗពិបាកនឹងមើលគ្នា ខ្ញុំឃើញរាងកាយនាងតែត្រឹមមួយកំណាត់លើ ហើយនិងសរសៃសក់នាងដ៏វែងរំសាយបក់រវិចទាំងគ្មានខ្យល់អីបន្តិចណា។

បន្ទាប់មក នាងហាក់កំពុងច្រៀង ឬយំកំណត់ក៏មិនបាន ព្រោះខ្ញុំគាំងធ្មឹងដោយក្ដីតក់ស្លុត។ ជាលើកដំបូងក្នុងជីវិតដែលខ្ញុំត្រូវមកចរចាប្រឈមមុខផ្ទាល់ជាមួយខ្មោច។

ជង្គង់របស់ខ្ញុំទន់លំលៃល្មមធ្វើឱ្យរាងកាយរបស់ខ្ញុំខ្សោយ ស្ទើរតែធ្លាក់ស្រុញចុះ តែខ្ញុំនៅតែអាចបន្តឈរបានមិនដឹងព្រោះតែថាមពលអ្វីឡើយ។ ក្នុងពេលជាមួយគ្នានេះ ខ្ញុំក៏គិតក្នុងចិត្តផងដែរ ថាអ្វីដែលខ្ញុំបានឮ និងកំពុងឃើញនេះគឺជាសុបិន មិនមែនជាការពិតឡើយ។

«អ្នកឯងព្រាយមែនទេ?»

ខ្ញុំនិយាយម្ទួបៗទាំងអណ្ដាតបាក់បបក្រោមភាពរន្ធត់ខ្លបខ្លាច។

«ខ្ញុំមិនខ្លាចទេ! មកតាមខ្ញុំធ្វើស្អី?»

ខ្ញុំមិនដឹងថានាងជានរណា ឬតើនាងត្រូវការអ្វីនោះទេ ប៉ុន្តែខ្ញុំគិតថាស្ថានភាពនាងដូចជាកំពុងត្រូវការជំនួយច្រើនជាងមកយាយី។ ចម្លែកបំផុត ពេលខ្ញុំសួរ នាងបែរជាមិននិយាយអ្វីឆ្លើយតបមកវិញសោះ។

«ខ្ញុំសួរថាអ្នកឯងមកពីដើមបំពេញរាជ្យនោះមែនដែរទេ? អ្នកឯងតាមខ្ញុំមកធ្វើអ្វី?»

នៅទីបំផុត ខ្ញុំបានឃើញនាងរលាយរូបបាត់ទៅយ៉ាងស្ងប់ស្ងាត់ សល់នៅតែឡានស្ទូចរបស់ខ្ញុំដែលឈរចង្រ្គាងកណ្តាលពន្លឺមេឃងងឹតស្រពេចស្រពិល។

ដឹងខ្លួនមកវិញ ទ្រនិចនាឡិកាកណ្តាលផ្ទះចង្អុលម៉ោង ១១ យប់។

គឺម្តាយខ្ញុំនៅក្បែរបង្អើយ គាត់កំពុងដាស់ខ្ញុំឱ្យក្រោកទៅគេងក្នុងបន្ទប់ឱ្យស្រួលបួល។

ខ្ញុំក្រោកមួយៗទាំងក្នុងចិត្តបានបង្កប់ចម្ងល់ និងសំណួរជាច្រើន។ ម៉ែបម្រុងនាំខ្ញុំទៅបន្ទប់របស់ខ្ញុំដែលគាត់បានចងមុងទុកឱ្យ តែខ្ញុំបែរជាដើរទៅប្រះគ្រាំងលើគ្រែរបស់គាត់ បង្ហាញថាខ្ញុំនឹងគេងនៅនេះជាមួយគាត់។

«ខ្ញុំយល់សប្តិឃើញមនុស្សស្រីឈរក្បែរឡានស្ទូច និយាយពាក្យដដែលៗថាចង់ឱ្យខ្ញុំរកកូនមកឱ្យគេ!»

ម្តាយខ្ញុំមិនមាត់ គាត់អង្អែលក្បាលខ្ញុំ។

មុនពេលខ្ញុំលក់ គាត់សួរតិចៗ៖

«មិនរកបាយទឹកទេអ្ហីកូន?»

«អាសាន់វាស៊ីហើយឬនៅ?»

«ពួកម៉ាកកូនឯងទៅក្លែមជាមួយអាឌីននៅផ្ទះតាពេជ្រ!»

តាពេជ្រជាគ្រួសារដែលមានកូនប្រុសច្រើនជាងគេក្នុងភូមិ ដូច្នេះផ្ទះគាត់ជាទីជំនុំផឹកស្រាជាទីពេញនិយមសម្រាប់ពួកយុវវ័យដូចខ្ញុំ រាល់ពេលដែលត្រឡប់មកលេងផ្ទះ ប៉ុន្តែលើកខ្ញុំហាក់គ្មានអារម្មណ៍ទេ។

«ចាំឃ្លាន ចាំខ្ញុំក្រោកទៅហូប!»

បន្ទាប់ពីនោះ ខ្ញុំលង់លក់ភ្លឹងមិនដឹងខ្លួន និងគ្មានយល់សប្តិអ្វីទល់ភ្លឺមាន់រងាវលាន់រំពងពេញភូមិ។ ដោយក្រោកមកខ្ញុំឃើញអាសាន់វានៅដេកក្រវៀនៗព្រោះពុលស្រាធ្ងន់ដែយប់មិញ ខ្ញុំក៏ខ្ជិលដាស់វា។

ទាំងព្រលឹមត្រជាក់ ពុកខ្ញុំ ម៉ែខ្ញុំ និងខ្ញុំ មានបងឌីនជាអ្នកដឹកធ្វើដំណើរទៅកន្លែងតាជន្ទល់ខ្មៅដោយឆ្លងកាត់តាមភូមិករ និងវាលស្រែជាច្រើន។ នៅតាមផ្លូវ គ្មានអ្នកណានិយាយលេងអ្វីដូចលើកមុនៗទេ។

ដោយស្ងាត់ពេក ខ្ញុំហើបមាត់សួរបងឌីន៖

«កាលមកពីកាប់ដើមបំពេញរាជ្យនៅភូមិលិច បងឯងមានដែលយល់សប្តិឃើញអីប្លែកៗដូចខ្ញុំដែរអត់?»

«មានតែម្តងគត់!»

បងឌីននិយាយតប ធ្វើឱ្យម្តាយខ្ញុំដេញសួរនាំ៖

«យល់សប្តិម៉េចខ្លះកូន?»

បងឌីនងាកមកក្រោយបន្តិច ហើយរៀបរាប់៖

«ខ្ញុំឃើញអាដួចវាទិញបានផ្ទះថ្មីមួយ ហើយវាហៅខ្ញុំឱ្យទៅជួយធ្វើសួនជាមួយវា! ខ្ញុំឃើញថាខ្លួនឯងបានស្នាក់នៅក្នុងផ្ទះនោះ មិនច្បាស់ថាឈើ ឬថ្ម ដឹងតែថាធំណាស់ ល្វឹងតែម្តង។ ឃើញខ្លួនឯងខំឆ្ការព្រៃធ្វើសួនឡើងស្អាត ស្រាប់តែចេញពីផឹកទឹកមកវិញ ឃើញសំរាម និងស្លឹកឈើចាស់ៗធ្លាក់មកគ្របដណ្តប់កខ្វក់ពេញជុំវិញផ្ទះ។ ខ្ញុំនិយាយនឹងអាដួចថា មិនចង់ឱ្យវានៅកន្លែងហ្នឹងទេ តែវាមិនព្រមស្តាប់ ហើយខ្ញុំស្តីឱ្យវាទៀតថា បើឯងនៅរឹងក្បាល អញប្រាប់ពុកម៉ែ! ស្រាប់តែវាលូកដៃមកច្រានខ្ញុំចូលស្រះទឹកត្រជាក់សឹងកក! ខ្ញុំមានដែលដេកម៉ាស៊ីនត្រជាក់ពីអង្កាល់ ហេតុអ្វីបានជាមានយល់សប្តិឃើញត្រជាក់សឹងកកឈោមកើត?»

«តែយល់សប្តិហ្នឹងទាក់ទងអីជាមួយរឿងព្រាយដែលខ្ញុំឃើញ?»

ខ្ញុំសួរបងឌីនទាំងតប់ប្រមល់ ព្រោះនៅមិននៅ ខ្ញុំទៅតូចចិត្តអាក្រក់ជាច្រានគាត់ចូលស្រះអីឯណា?

«និយាយទៀតមកកូន! និយាយឱ្យចប់ ឯងឃើញម៉េចទៀត?»

បងឌីនធ្វើមុខស្មើស្លេក គាត់មើលទៅទិសដៅខាងមុខបណ្តើរ និយាយរៀបរាប់បណ្តើរ៖

«ក្នុងទឹក ខ្ញុំស្រវាតោងបានដើមឈើមែកឈើជាច្រើនដែលបង្កប់ក្នុងស្រះនោះ ហើយច្រមុះខ្ញុំធុំក្លិនមហាសែនឈ្ងៀម។ ខ្ញុំត្រដេត្រដរតោងឡើង ភ្នែកសម្លឹងរកអាដូចមិនឃើញវាសោះ តែឃើញផ្ទះថ្មមួយទៅវិញ! ផ្ទះនោះមិនដូចសំណង់ឈើផ្សេងៗនៅស្រុកខ្មែរយើងសោះ ប៉ុន្តែមានព្រៃឈើស៊ុបទ្រុបព័ទ្ធជុំវិញ។ ខ្ញុំទន្ទេញធម៌ត្រដាបត្រដួសផង តោងឡើងមកគោកផង ហើយរត់ចោលកន្លែងនោះតែម្តង។ បានពាក់កណ្តាលផ្លូវ ក៏លេចចេញក្មេងស្រីតូចម្នាក់សក់វែងហៀរគ្របមុខអង្គុយយំម្នាក់ឯង។ ខ្ញុំខ្លាចណាស់មិនចង់ឈប់សួរនាងទេ តែជើងដូចរត់មិនរួចសោះ រហូតដល់នាងងើបមុខឡើងមក មុខក្មេងស្រីនោះពិតជាអាក្រក់ខ្លាំង អាចធ្វើឱ្យខ្ញុំភ័យញ័រខ្លួនចំប្រប់ ស្រែកមិនចេញរហូតដឹងខ្លួនធ្លាក់ចុះលើគ្រែ។»

ខ្ញុំកត់សម្គាល់ឃើញរោមដៃខ្ញុំហាក់បះច្រូងជាមួយសរសៃឆ្មារៗស្ទើងៗ ហើយមានសញ្ញាភ័យព្រួយក្នុងចិត្តយ៉ាងចម្លែក។ ខ្ញុំត្រូវតែទទួលស្គាល់ក្នុងចិត្តស្ងាត់ៗម្នាក់ឯងថា កាលដែលបានទៅអង្គុយមើលគេធ្វើពិធីបរព្រៃគ្រានោះ មានឥទ្ធិពលនាំមកនូវបណ្តារឿងអពមង្គលទាំងប៉ុន្មានដែលពួកខ្ញុំបានប្រឈមក្នុងពេលនេះ ពិតណាស់។

ផ្ទះតាជន្ទល់គ្មានភ្ញៀវរង់ចាំច្រើនដូចដែលខ្ញុំបានគិតពីចម្ងាយមកនោះទេ។ គ្រាន់តែឡានឈប់ភ្លាមគាត់បង្ហាញខ្លួនពីក្នុងផ្ទះដោយបក់ដៃហៅពួកយើងពីចម្ងាយ។

«ម៉ែបានខលមកគាត់មុនមែនអត់?»

ខ្ញុំខ្សឹបសួរ ហើយដំអក់នៅក្នុងឡានដដែល ចំណែកប៉ាខ្ញុំ គាត់ចុះទៅមុន។

«ម៉ែមានបានខលមកអី? មានលេខពីណាមក!»

ម៉ែឆ្លើយខ្លីៗព្រោះប្រញាប់ចុះទៅរកម្ចាស់ផ្ទះដែលដើរចេញមកទទួលពុកខ្ញុំ។ គាត់ពិតជាតាជន្ទល់ខ្មៅពិតណាស់។

«ចុះមកកូន!»

ពួកយើងចូលមកដល់ក្នុងបរិវេណផ្ទះ តែមិនបានចូលទៅកាន់បន្ទប់តាជន្ទល់ខ្មៅទេ មានតែម៉ែ ហើយនិងពុកខ្ញុំដែលគេឱ្យចូលទៅមុន។ ខ្ញុំ និងបងឱន គេឱ្យអង្គុយចាំលើគ្រែឫស្សីមួយ។

បរិវេណផ្ទះនេះមានការបោសសម្អាតស្អាតបង្ហាញពីចរិតរស់នៅប្រកបដោយអនាម័យរបស់ម្ចាស់ផ្ទះ ប៉ុន្តែគ្មានឃើញកន្លែងណាមួយបង្ហាញថាអំពើអំពាន់អ្វីសោះ សង្ឃឹមដូចម្តេចថាពួកគេអាចដោះស្រាយរឿងរបស់ខ្ញុំបាន។

«បងឌីនឯងឧស្សាហ៍ទៅឃើញគេបរព្រៃអ៊ីចឹងប៉ុន្មានដងហើយ?»

ខ្ញុំសួរបងធម៌ដែលអង្គុយច្រងុំកៗ។ គាត់គិតបន្តិច ទើបឆ្លើយតបវិញ៖

«កាលទៅជាមួយឯងងហ្នឹង ជាបរព្រៃធំជាងគេដែលបងធ្លាប់ឃើញ!»

ខ្ញុំខិតចូលទៅកៀកគាត់ មុនពេលខ្សឹបខ្សៀវបន្ត៖

«នែ៎បងឯងនៅផ្ទះច្រើនជាងខ្ញុំ បងឯងដែលឮគេនិយាយរឿងខ្មោចមនុស្សស្រីសួររកកូនរកអីអត់បងឌីន?»

«ឱ្យតែខ្មោច វាច្រើនតែសួររកកូនវាទាំងអស់ហ្នឹងអ្ហ៎!»

«ខ្ញុំចង់ដឹងថា បងឯងធ្លាប់ឃើញអត់?»

«បងឮតែចាស់ៗនិយាយហ្នឹង! គាត់ថា ពេលថ្ងៃត្រង់ខ្មោចបំពេកូនវា ព្រលប់ៗខ្មោចដើររកកូនវា ព្រោះកូនវាដើរលេងច្រើនវង្វេងរកផ្លូវមកវិញមិនឃើញ!»

ខ្ញុំលែងមាត់ចាប់ផ្ដើមព្យាយាមរម្លឹកនឹកឃើញឡើងវិញរាល់សម្ដីរបស់តាអាចារ្យឈ្មោះសច្ចា។

«ព្រាយនោះតាមមកប្រហែលមានអ្វីឱ្យចៅឯងជួយគេ!» «ព្រាយនោះចេញមកពីដើមឈើធំមួយ!»។

បងឌីននិយាយបន្ថែមប្រហែលជាមកពីឃើញខ្ញុំនៅស្ងាត់យូរពេក៖

«យប់មិញមកដល់ផ្ទះហើយ មានបានឡើងអុជធូបបន់ជីដូនជីតាអីខ្លះអត់?»

មិនមែនខ្ញុំមិនមានជំនឿអ្វីទៅលើរឿងគោរពគ្រូបាធ្យាយជីដូនជីតាអ្វីនោះទេ ណាស់តែខ្ញុំខ្ជិល។ មានរឿងប៉ុណ្ណេះហើយ យប់មិញមកដល់ផ្ទះក៏មិននឹកឃើញឡើងទៅរកអុជធូបអីសោះបែរជាដាក់ខ្នងភ្លាមដេកលក់ភ្លឹប។ ចង់ឱ្យមានអ្នកតាមថែរក្សាឯណា បើម្នាលខ្លួនខ្ជិលមហាបែបនេះ។

ខ្ញុំនឹកឃើញសួរបងឌីនបកវិញ៖

«បង! ជឿថា តាពេជ្រលបដាក់សាច់ឆ្កែក្នុងសាច់ក្លែមអត់?»

«វាមិនដែល! បើគាត់ដាក់ បងដឹងភ្លាម! អ្ហូអាដូច! អ្ហែងកុំលឱ្យសោះ អារឿងសាច់ឆ្កែ! ឱ្យតែប៉ះ យីអ៊ុនដាក់យកតែម្ដងអ្ហ៎! បងធ្លាប់កាលពីក្មេង រាងម៉ាជីវិត អាដូច!»

ខ្ញុំញក់ញីក្បាលទាំងពិបាកក្នុងចិត្ត ហើយនិយាយសារភាពប្រាប់គាត់៖

«ខ្ញុំប្រហែលស៊ីប៉ះវាហើយ! អាចារ្យនៅភ្នំពេញ គេថា ខ្ញុំនេះមានក្លិនសាច់ឆ្អៅ ហើយថាធ្លាប់ដើរក្រោមស្នួខោអាវគេទៀត! ខ្ញុំខ្លួនឯងរកនឹកមិនឃើញសោះ!»

ពុកម៉ែខ្ញុំដែលចូលទៅមួយសន្ទុះ ក៏ចេញមកវិញ។ ពុកមកកេះខ្ញុំឱ្យចូលទៅជួបតាជន្ទល់ខ្មៅ ខ្ញុំក៏ក្រោកក្រេះចូលទៅតាម។ ពីក្រោយខ្នងខ្ញុំ ម៉ែបង្គាប់ទៅបងឌីនយ៉ាងរួសរាន់៖

«ជូនម៉ែទៅផ្សារទិញរណ្ដាប់រៀបពិធីអាឌីន!»

តាជន្ទល់ខ្មៅញញឹមស្រស់ទទួលខ្ញុំ។

គាត់ចង្អុលឱ្យខ្ញុំអង្គុយលើកន្ទេល ហើយពុកខ្ញុំមកពីចំហៀង។

«ជួបតាហើយ មិនបាច់ភ័យអីទាំងអស់!»

គាត់និយាយត្រឹមប៉ុណ្ណឹង ចិត្តខ្ញុំធូរខ្សាក។ ខ្ញុំលើកដៃសំពះ ពេលគាត់ហុចធូបមួយសំណុំមក។

«ដុតទៅ! ហើយបួងសួងហៅជីដូនជីតាគ្រូបាអាចារ្យឱ្យមកជុំគ្នា!»

គាត់បង្គាប់ ហើយខ្ញុំក៏ធ្វើតាម។ ពេលអុជធូបឆេះទ្រុលផ្សែងហើរខ្ចួលហើយ ខ្ញុំវិលមកអង្គុយបត់ជើងនៅទីកន្លែងដដែលវិញ តាជន្ទល់ខ្មៅគាត់ក៏មកនៅទល់មុខខ្ញុំទៀតដោយអង្គុយចុះដូចគ្នា ហើយនិយាយអប់រំខ្ញុំ។

«បន្តិចទៀត តាមានពិធីលាងក្លិនអាក្រក់ចេញ! ហើយពេលម៉ែឯងមកវិញ តាធ្វើពិធីរំដោះស្រមោលអន្ទោលឱ្យ!»

«ស្រមោលអន្ទោលជាស្អីទៅលោកតា?»

ខ្ញុំត្រូវតែកាត់សួរ ព្រោះថាបើមិនឱ្យខ្លួនឯងដឹងរឿងច្បាស់ពេលនេះ តើរង់ចាំពេលណាទៀត?

«ព្រាយស្រីមួយនៅតោងជាប់ជាមួយឡានស្ទូចរបស់ពុកឯង! គេចេញពីដើមបំពេញរាជ្យ ហើយតែលតោលបាត់គ្រួសារ! ពេលរួចពីនេះ ពុកឯងនឹងទៅកន្លែងចាស់នោះ សែនរកកូនឱ្យគេវិញ ឯងមិនបាច់ទៅទេ ព្រោះរាសីមិនទាន់ល្អ! ចាស់ៗគេចេះធ្វើហើយ! ចំណែកល្ងាចនេះ ពេលដេញស្រមោលអន្ទោលរួច តាទៅភូមិជាមួយឯងទៅសែនក្បាលឡានស្ទូចមួយជាន់ទៀត ទុកជាការស្រេចបាច់!»

ខ្ញុំស្ដាប់មិនទាន់ទេ ព្រោះវាច្រើនណាស់សម្រាប់ខ្ញុំ អ្វីដែលខ្ញុំអាចកាត់យល់បានខ្លះៗគឺថាអ្នកនៅចំពោះមុខខ្ញុំនេះ គាត់មានមូលហេតុច្បាស់លាស់ ឈានទៅរកដំណោះស្រាយមួយឱ្យខ្ញុំកក់ក្ដៅឡើងវិញបាន។

ទោះយ៉ាងណា គាត់មិនទាន់រៀបចំពិធីទេ ដូច្នេះខ្ញុំមានពេលចាក់សំណួរបន្ថែម៖

«ស្រីម្នាក់នោះជាព្រាយ? អ្នកភូមិឃើញខ្ញុំដឹកមនុស្សស្រីទៀត ខ្ញុំស៊យណាស់ ខ្ញុំស្មុគចិត្តណាស់លោកតា!»

តាជន្ទល់ខ្មៅញញឹមបិទភ្នែក តែបានពុកខ្ញុំជាអ្នកបកស្រាយពន្យល់៖

«ពេលគាត់ដោះស្រាយហើយ លែងអីហើយ! ពុកជម្រាបគាត់អស់ហើយ! គាត់ប្រាប់ថា ស្រីនោះជាស្រមោលទេ គេតាមកូនឯងដោយសារតែរាសីយើង! គាត់មានវិធីបណ្ដេញ! ចាំម៉ែឯងទិញរណ្ដាប់មកសិន!»

ពុកនិយាយមិនទាន់ចប់ គាត់ក៏បើកភ្នែកមកវិញ ហើយបង្គាប់៖

«តោះ លាងក្លិនចេញពីខ្លួន!»

ខ្ញុំលែងសួរ តែនឹកឃើញដល់សម្ដីតាសច្វាពីរឿងសាច់ឆ្អែតជានិច្ច។ ស្ត្រីម្នាក់មានរូបរាងទាបធាត់ លើកផើងទឹកមួយចូលមក។

លោកតាជន្ទល់ខ្មៅទទួលយក ហើយចាប់ផ្ដើមសូត្រធម៌ប្រោះព្រំមកលើខ្ញុំ។ ទឹកមន្តនោះមានក្លិនក្រអូបឆ្អួលដោយទឹកអប់ និងកម្ទេចលម្អងផ្កាដូចដែលខ្មែរយើងនិយមប្រើក្នុងពិធីសូត្រមន្តលើករាសីដែរ។ ខុសគ្នាត្រង់ថា គាត់បង្គាប់ឱ្យពុកទទួលកំបោរក្រហមមួយចានយកមកលាបពេញមុខខ្ញុំ រហូតដល់ដើមក កញ្ចឹងក និងម្រាមដៃខ្ញុំទាំងដប់ដែលកំពុងប្រណម។

គាត់សូត្រផង ផ្លុំផង ហើយបាញ់ទឹកអប់ដាក់រាងកាយខ្ញុំ។

ប្រមាណ ១០ នាទី ទើបធម៌នោះចប់។

តាជន្ទល់ខ្មៅ និងពុកនាំខ្ញុំចេញពីផ្ទះទាំងរាងកាយប្រឡាក់ស្រមក។ គាត់កាន់បំពង់ឫស្សីប្រវែងប្រហែលមួយកំភួនដៃមនុស្សចាស់ ចំណែកពុកខ្ញុំឱបមកជាមួយនូវផើងទឹកដែលនៅសេសសល់។

នៅក្រោយផ្ទះគាត់ មានជណ្ដើរចុះទៅមាត់ស្រះមួយធំគួរសម។ គាត់ឱ្យខ្ញុំចុះជណ្ដើរ ៧ កាំ ហើយប្រគល់ផើងទឹកដែលនៅសល់ឱ្យមកខ្ញុំទូលលើក្បាល។ គាត់បង្គាប់៖

«អាចៅឯងចាំនិយាយតាមតាគ្រប់ម៉ាត់!»

ខ្ញុំទូលផើងទឹក បែរមុខទៅស្រះ ហើយអង្គុយធ្មេចភ្នែកត្រងត្រាប់ស្ដាប់សម្ដីគាត់។ មិនយូរប៉ុន្មាន គាត់ចាប់ផ្ដើមគោះបំពង់ឫស្សីនៅលើដៃបង្កជាចង្វាក់ភ្លេងលាន់ឡើងទ្រហឹងអឹងអាប់។

ភ្លេងលេងបានបន្តិច គាត់ផ្ដាំខ្ញុំទៀត៖

«និយាយតាមតា!»

ខ្ញុំផ្ទង់អង្គុយត្រង់ខ្លួន ចំណែកគាត់ចាប់ផ្ដើមនិយាយឮៗ៖

«បរមី ៨ ទិស រុញច្រានក្លិនអសោចកម្មផល អំពើមិនល្អ រឿងងងឹតងងុលចុះទៅទឹកស្រះឱ្យអស់រលីងធេងពីខ្លួនខ្ញុំពេលនេះអំណើះតទៅ!»

ខ្ញុំនិយាយតាមគាត់មិនហ៊ានឱ្យរំលងសូម្បីតែមួយដង្ហើមណា។ ចុងក្រោយ គាត់លូកដៃមករុញច្រានកំពប់ទឹកនោះស្រោចមកលើខ្លួនខ្ញុំអសារបង់ទៅក្នុងស្រះទាំងអស់។

ទឹកស្រក់បានបន្តិច តាជន្ទល់ខ្មៅក៏ហៅខ្ញុំឱ្យក្រោកឡើងមកវិញ។

«ខ្លួនប្រាណស្អាតបាត់ហើយ សមល្មមអាចនឹងទៅប្រកួតបណ្ដេញស្រមោលអន្ទោលនោះបានហើយ!»

ខ្ញុំយល់ខ្លះមិនយល់ខ្លះនូវបណ្ដាពាក្យចម្លែកៗរបស់គាត់ តែជម្រើសរបស់ខ្ញុំគឺធ្វើតាមតែគាត់ប្រាប់ប៉ុណ្ណោះ។

មកដល់ផ្ទះវិញ គាត់ឱ្យខ្ញុំស្លៀកសារុងមួយពណ៌លឿងទែង ហើយដោះខោអាវដែលទទឹកនោះចងមួយដុំ ឱ្យពុកខ្ញុំយកទៅបណ្ដែតទឹកកន្លែងណាក៏ដោយដែលមានទឹកហូរលឿន។

កំបោរនៅជិតដាមរាងកាយខ្ញុំ ហូរហៀរខ្លះ កកជាប់ខ្លះ។

ខ្ញុំឡើងមកកន្លែង ក៏ឃើញបងឌីន និងម៉ែកំពុងរៀបចំក្អមតូចៗជាច្រើនប៉ុនកូនឪឡឹកដែលមានអង្ករពេញៗ។ ក្រៅពីនោះគឺពំនូកខ្សាច់ធំមួយនៅចំកណ្ដាល។

តាជន្ទល់ខ្មៅអុជធូបបីដើមទៀតលើពំនូកខ្សាច់ ហើយបង្គាប់ឱ្យខ្ញុំចូលអង្គុយនៅចំពីមុខពំនូកនោះ។

«ចន្ទាឯងលើកដៃភាវនា ហើយធ្មេចភ្នែករម្លឹកគុណជីដូនជីតា បើតាមិនឱ្យបើកភ្នែកទេ កុំបើកឱ្យសោះ!»

ខ្ញុំធ្វើតាមគាត់ទាំងអស់ ដូច្នេះខ្ញុំលែងឃើញអ្វីទៀតហើយ បានត្រឹមប្រើត្រចៀកធ្វើជាមធ្យោបាយសម្គាល់គ្រប់យ៉ាងជុំវិញខ្លួន។ ខ្ញុំចាប់ផ្ដើមឮគេចាក់ពិណពាទ្យ ហើយគ្រប់យ៉ាងស្ងាត់គ្មានសំឡេងអ្នកណាឆ្លងឆ្លើយទាំងអស់។

តាជន្ទល់ខ្មៅប្រហែលកំពុងរាំចូលរូបនេះ បើតាមការស្មានរបស់ខ្ញុំ។

មិនខុសទេ មិនយូរប៉ុន្មាន គាត់ចាប់ផ្ដើមបញ្ចេញសំឡេងនិយាយញ៉ិកញ៉ក់ ដូចកាលពីមនុស្សស្លៀកក្បិនប្រារព្ធបវេ្រៃអុីចឹងដែរ តែគាត់និយាយញាប់ណាស់មិនដូចតាសច្ចានៅផ្ទះជាន់ទីបីដែលនិយាយភាសាកូនក្មេងឃីតៗអន្លាយៗនោះទេ។ គាត់និយាយចុះឡើងយូរណាស់ គឺយូរដល់ខ្ញុំត្រូវងោកមួយសាៗ។

ខ្ញុំស្មានមើលការស្រែកឡូឡានិយាយដូចកូនក្មេងមិនដឹងក្បាលកន្ទុយនោះ ទំនងជាស៊ីពេល ១៥ នាទីយ៉ាងហោចណាស់ អុីចឹងហើយខ្ញុំឱនទៅៗសឹងថាអស់កម្លាំងប្រាណដួលដេកទាំងងោកងុយព្រោះតែទ្រាំលែងចង់បាន។

ផសៗ គឺស្នូរវាយក្អមបំបែក។ គ្រាប់អង្ករជាច្រើនខ្ទាតរកាំមកលើភ្លៅខ្ញុំ ធ្វើឱ្យភ្ញាក់សឹងថាច្រឡំបើកភ្នែកមកវិញម្ដងៗទៅហើយ តែខ្ញុំទ្រាំណាស់ទម្រាំគាត់ឈប់សូត្រ ឈប់វាយក្អម និងបញ្ឈប់បទភ្លេង។

«បើកភ្នែកមកចន្លា!»

ខ្ញុំភ្ញាក់ពីភាពធុញថប់ហត់នឿយ។

តាជន្ទល់ខ្មៅហូរញើសដូចគេស្រោចទឹកធុង។ គាត់អង្គុយនិយាយផ្ងូងៗចំពីមុខខ្ញុំ៖

«នៅពេលគេធ្វើពិធីអ្វីក៏ដោយឱ្យតែទាក់ទងនឹងការហៅខ្មោចព្រាយ គេហាមដាច់ខាតមិនឱ្យមនុស្សដែលយីអ៊ុនដាក់រាសីខ្សោយទៅអង្គុយមើលក្នុងចំណោមអ្នកធ្វើពិធីទេ ព្រោះព្រាយវិញ្ញាណដែលហើរចេញមកនោះ វង្វេងវង្វាន់រកកន្លែងពួនលាក់អាត្មាមិនបាន ក៏ចរច្រប់រសាត់ឥតគោលដៅតាមពីក្រោយអ្នកនោះ! មុននេះ ព្រះគ្រូបានបណ្ដេញព្រាយនោះចេញឱ្យ ហើយដោយលោកបានចង្អុលប្រាប់ពីកូនរបស់គេថានៅកន្លែងណាផងដែរ! ខ្លួនចន្លាឯងមានក្លិនអសោចសាច់មិនគួរសេព ពេលនេះបានជម្រះស្អាតតាមទឹកអស់ដូចគ្នា! ពីពេលនេះ ចូរសាងអំពើល្អ តម្កល់គុណឪពុកម្ដាយជាធំទៅណាមកណា ហាមសេពគប់មិត្តមិនរើសមុខ ហាមស៊ីផឹកឡូឡាមិនប្រុងប្រយ័ត្ន ហាមរម្លឹករឿងព្រាយនោះទៀត!»

ខ្ញុំអរភើតក្រឡេកសម្លឹងជុំវិញខ្លួនរកមើលថាអ្នកណាទៅជាព្រះគ្រូនោះ មិនឃើញអ្វីក្រៅតែពីសំណល់ក្អមបែករាយប៉ាយអង្គរពាសពេញផ្ទះ។

«ធីឯងនាំកូនទៅផ្ទះវិញ! យកខោអាវមួយស្បោងនោះចោលតាមផ្លូវ កុំទុកឱ្យដល់ផ្ទះទាន់។ ប្រមូលអង្ករទាំងនេះមួយថ្នក់ទុកបាចលាគ្នាជាមួយពួកវិញ្ញាណនានាឱ្យចប់ដាច់ស្រេច។ ចូរសុខសប្បាយ!»

យប់នោះ ខ្ញុំវិលមកភូមិ ហើយអុជធូបជូនជីដូនជីតាសម្រាកស្កប់ស្កល់ដល់ភ្លឺជាមួយម៉ែពុកខ្ញុំ។ គ្មានអ្នកណាក្នុងផ្ទះយើងនាំគ្នារម្លឹកឡើងវិញអំពីរឿងទាំងអស់នោះទៀតទេ ពិសេសសូម្បីតែទស្សនារឿងខ្មោច ឬនិយាយពីរូបភាពហេតុភេទអាក្រក់ផ្សេងៗដែលគេនាំគ្នាផុសតាមហ្វេសប៊ុក ក៏ម្ដាយខ្ញុំហាមប្រាមជានិច្ច។

ខ្ញុំវិលមកភ្នំពេញវិញជាមួយនឹងការតាំងចិត្តថាខំរៀនលែងចូលរួមផឹកស៊ីមួយរយៈ។

៧ ថ្ងៃក្រោយមក...

«អាថា អ្ហែងមុខញញឹមប្រិមប្រិយម៉េះអ្ហ៎?»

អាសាន់មកដល់ពីក្រោយខ្នងខ្ញុំ ចំពេលខ្ញុំកំពុងតែជក់ចិត្តជាមួយហ្វេសប៊ុក។

«អញឃើញស្រីម្នាក់ អានេះ!»

ខ្ញុំនិយាយទាំងបេះដូងកក់ក្ដៅ ព្រោះនិស្សិតទើបនឹងចូលថ្មីម្នាក់ចតម៉ូតូក្បែរខ្ញុំកាលរំលងប៉ុន្មានថ្ងៃមុន។ សម្រស់ និងភាពរមទមស្រពាប់ស្រពោនរបស់នាងពិតជាធ្វើឱ្យបេះដូងយុវជនដូចខ្ញុំត្រូវរង្គោះរង្គើមែន ដល់ថ្នាក់ចាំបាច់ត្រូវមកពួនលបបើកមើលហ្វេសប៊ុករបស់គេស្ងាត់ៗម្នាក់ឯង។

តែអាសាន់មិនយល់ពីអ្វីដែលខ្ញុំកំពុងគិតទេ ឮសម្ដីខ្ញុំកាលណា វាបែរជាភ័យស្លេក ហើយសួរញ័រមាត់៖

«ក្រែងអាទិត្យមុន អ្ហែងថា តាជន្ទល់ខ្មៅបណ្ដេញព្រាយដើមឈើទៅបាត់ហើយ?»

ខ្ញុំទើបនឹងយល់ច្បាស់ថា វាកំពុងគិតពីរឿងអ្វី? តាមពិត ខ្ញុំបំភ្លេចរឿងព្រាយបាត់កូននៅដើមបំពេញរាជ្យនោះបាត់ទៅហើយ ពេលនេះអាសាន់ដូចជានៅដិតដាមជាមួយរឿងនោះនៅឡើយ។

ខ្ញុំលើកហ្វេសប៊ុកស្រីស្អាតដែលខ្ញុំ Search ឃើញនោះ បង្ហាញវា ចង់បញ្ជាក់ថា ខ្ញុំនិយាយអំពីមនុស្សពិតៗមិនមែនខ្មោចទេ។

«សែន សុខណានីន?»